# មាតិកា

**ទំព័រ**


**មេរៀនទី១ ៖..........................................................................០១**

*ឯកសារស្ដីពីការផ្សារត្រួតពិនិត្យការអនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ សេចក្ដីសម្រេចចិត្តនានារបស់គណបក្ស*

**I-គោលបំណង និងសារៈសំខាន់ជាមូលដ្ឋាននៃការងារត្រួតពិនិត្យ..........................................................................០១**

**II-គោលការណ៍ និងលិខិតូបករណ៍មូលដ្ឋានសម្រាប់ការងារត្រួតពិនិត្យ..........................................................................០៣**

**III-វិធីដំណើរការត្រួតពិនិត្យ ..........................................០៧**

*១.សមត្ថកិច្ចសិទ្ធិអំណាចត្រួតពិនិត្យ ..................................០៧*

*២.មុខសញ្ញាត្រួតពិនិត្យ ..................................................០៨*

*៣.ខ្លឹមសារត្រួតពិនិត្យ .....................................................០៨*

*៤.ការស្នើសុំគោលការណ៍គណៈកម្មាធិការគណបក្ស .........០៨*

*៥.ការកសាងផែនការដើម្បីដំណើរការត្រួតពិនិត្យ ...............០៨*

*៦.ជំហាននៃការអនុវត្តការត្រួតពិនិត្យ .................................០៩*

*៧.ការបូកសរុប វាយតម្លៃ និងសន្និដ្ឋាន ..............................០៩*

**មេរៀនទី២ ៖ ..........................................................១០**

*ឯកសារស្តីពីការផ្សារត្រួតពិនិត្យអង្គការចាត់តាំង និងមន្ត្រី សមាជិកគណបក្ស ប្រព្រឹត្តល្មើសវិន័យគណបក្ស*

**I-សេចក្តីផ្តើម ..........................................................១០**
**II-អំពីវិន័យរបស់គណបក្ស..........................................................១២**
១.ទស្សនាទានអំពីវិន័យ ..........................................................១២
២.ខ្លឹមសារនៃវិន័យ ..........................................................១៤
៣.ទិសដៅនៃការដាក់វិន័យ ..........................................................១៥
៤.លក្ខខណ្ឌនៃការដាក់វិន័យ..........................................................១៦
៥.ទម្រង់បែបបទនៃការដាក់វិន័យ ..........................................................១៨
ក.ការទទួលខុសត្រូវចំពោះសាខាគណបក្ស..........................................................១៩
ខ.ការវាយតម្លៃកំហុស និងវិន័យ..........................................................២០
គ.សិទ្ធិរបស់មន្ត្រី សមាជិក និងអង្គការចាត់តាំងគណបក្សទទួលរងវិន័យ..........................................................២០
៦.រូបភាពវិន័យនិងការដាក់វិន័យ..........................................................២២
ក.រូបភាពវិន័យ ..........................................................២៣
ខ.ការដាក់វិន័យ ..........................................................២៣
គ.មុខសញ្ញាត្រួតពិនិត្យ ..........................................................២៨
ឃ.ខ្លឹមសារត្រួតពិនិត្យ ..........................................................២៨

ង.នីតិវិធីដំណើរការពិនិត្យវិនិច្ឆ័យដាក់វិន័យ..................៣៣
**III-នីតិវិធីនៃការត្រួតពិនិត្យកេរមុខសញ្ញាខុសឆ្គង..............៣៥**
១.វិធីដំណើរការស្រាវជ្រាវ..........................................៣៦
២.ការប្រកាសសេចក្ដីសម្រេចដាក់វិន័យ...........................៣៧
**IV-សមត្ថកិច្ចដាក់វិន័យ..........................................៣៨**
១.ចំពោះអង្គការចាត់តាំង............................................៣៨
២.ចំពោះសមាជិក......................................................៣៩
**V-ការរក្សាទុកសំណុំលិខិត.........................................៤៣**

**មេរៀនទី៣ ៖ .........................................................៤៤**

*ឯកសារស្ដីពីការទទួល និងដោះស្រាយបណ្ដឹង*

**I-សេចក្ដីផ្ដើម......................................................៤៤**
**II-បណ្ដឹងបរិហារ...................................................៤៥**
១.អត្ថន័យ..............................................................៤៥
២.ខ្លឹមសារ..............................................................៤៧
ក.បណ្ដឹងបរិហារត្រូវយកចិត្តទុកដាក់ដោះស្រាយ...............៤៨
ខ.បណ្ដឹងបរិហារដែលពុំគួរដោះស្រាយ.............................៤៩
៣.សមត្ថកិច្ចដោះស្រាយ...............................................៥០
ក.បញ្ហាដែលត្រូវចៀសវាង...........................................៥០
ខ.ករណីដែលត្រូវយកចិត្តទុកដាក់ ................................៥១

៤.កំណត់មុខសញ្ញា ............................................................ ៥១
៥.វិធីដោះស្រាយបណ្ដឹង ............................................................ ៥៣
ក.លក្ខការណ៍ដោះស្រាយបណ្ដឹង ............................................ ៥៣
ខ.ការបែងចែងប្រភេទបណ្ដឹងបរិហារ .................................... ៥៥
គ.អំពីការរៀបចំ ............................................................ ៥៥
ឃ.ផែនការសកម្មភាព ............................................................ ៥៧
ង.ការងារបញ្ចប់ការដោះស្រាយបណ្ដឹង ...................................... ៥៩
**III-បណ្ដឹងតវ៉ា** ............................................................ **៦០**
១.អត្ថន័យនៃបណ្ដឹងតវ៉ា ............................................................ ៦០
២.នីតិវិធីដោះស្រាយបណ្ដឹងតវ៉ា ............................................ ៦៣
ក.ការបែងចែកបណ្ដឹងតវ៉ា ............................................................ ៦៣
ខ.ផែនការសកម្មភាព ............................................................ ៦៤
គ.ពិនិត្យសម្រេច និងប្រកាសសេចក្ដីសម្រេច .......................... ៧០
**សេចក្ដីសន្និដ្ឋាន** ............................................................ **៧១**

# ឯកសារ
# ស្តីពីការខារត្រួតពិនិត្យការអនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ សេចក្តីសម្រេចចិត្តនានារបស់គណបក្ស

## I-គោលបំណង និងសារៈសំខាន់ជាមូលដ្ឋាននៃការខារត្រួតពិនិត្យ

*១.មហាសន្និបាតតំណាងទូទាំងប្រទេសរបស់គណបក្ស គឺជាអង្គការដឹកនាំខ្ពស់បំផុតរបស់គណបក្ស ដែលមានភារកិច្ចពិនិត្យពិភាក្សា និងអនុម័តលើរបាយការណ៍នយោបាយរបស់គណៈកម្មាធិការកណ្តាល អំពីសភាពការណ៍រួមរបស់គណបក្ស ហើយសម្រេចកំណត់ពីគោលនយោបាយក្នុងប្រទេស ក្រៅប្រទេស និងភារកិច្ចរបស់គណបក្សតាមដំណាក់កាលនីមួយៗ បំពេញបន្ថែម ឬកែសម្រួលលក្ខន្តិកៈគណបក្ស បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការកណ្តាលនៃគណបក្ស។*

*ការខារត្រួតពិនិត្យ មានតួនាទីយ៉ាងសំខាន់ក្នុងបណ្តាភារកិច្ចដឹកនាំរបស់គណបក្ស សំដៅរួមចំណែកក្នុងការកសាង និងការពង្រឹងគណបក្ស ដើម្បីធានាការអនុវត្តឲ្យបានត្រឹមត្រូវ និងជោគជ័យនូវកម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និង*

សេចក្ដីសម្រេចចិត្តនានារបស់គណបក្សនៅគ្រប់ថ្នាក់ គ្រប់ផ្នែក គ្រប់វិស័យ មន្ត្រី និងសមាជិកគណបក្សគ្រប់រូប។

ការដឹកនាំ បើខ្វះការត្រួតពិនិត្យ គឺមិនមែនជាការដឹកនាំពោលគឺ"**មានការដឹកនាំ គឺត្រូវមានការត្រួតពិនិត្យ**"។ ការត្រួតពិនិត្យនេះ គឺជាចំណែកមួយយ៉ាងសំខាន់ក្នុងការងារដឹកនាំរបស់គណបក្ស និងជាជីវភាពផ្ទៃក្នុងរបស់គណបក្ស ដែលចាំបាច់មិនអាចខ្វះបាន សំដៅពង្រឹងការឯកភាពខាងទស្សនៈនយោបាយ សតិអារម្មណ៍ ចាត់តាំង សាមគ្គីភាព និងសកម្មភាព ព្រមទាំងទប់ស្កាត់ និងបង្ការនូវបាតុភាពអសកម្ម ការធ្លាក់ក្នុងសតិអារម្មណ៍សន្តិភាពនិយម ស្កប់ស្កល់នឹងជ័យជម្នះ ស្ពឹកស្រពន់ ដែលធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិ ផលប្រយោជន៍ និងជំនឿរបស់ប្រជាជនចំពោះគណបក្ស។

២.ការងារត្រួតពិនិត្យការអនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងកម្មវិធីនយោបាយគោលការណ៍ គោលនយោបាយ និងសេចក្ដីសម្រេចចិត្តនានារបស់គណបក្ស ធ្វើឲ្យរកឃើញនូវចំណុចខ្លាំង ចំណុចខ្សោយ ព្រមទាំងគុណសម្បត្តិ និងគុណវិបត្តិដែលអង្គការចាត់តាំងគ្រប់ថ្នាក់ គ្រប់ផ្នែក គ្រប់វិស័យ មន្ត្រី និងសមាជិកគណបក្សគ្រប់រូប បាននិងកំពុងអនុវត្តដើម្បីលើកសរសើរជូនរង្វាន់តាមគ្រប់រូបភាព ដល់មន្ត្រី សមាជិក និងអង្គការចាត់តាំងគណបក្សដែលមានស្នាដៃល្អលេចធ្លោ និងមានវិធានការដាក់វិន័យយ៉ាងម៉ឺង

ម៉ាត់ចំពោះមន្ត្រី សមាជិក និងអង្គការចាត់តាំងគណបក្សដែលប្រព្រឹត្តល្មើសខុសឆ្គង។

៣.ពង្រឹងយន្តការការងារត្រួតពិនិត្យរបស់អង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ឲ្យមានប្រសិទ្ធភាព និងគុណភាព ដើម្បីលើកកម្ពស់ការតាំងចិត្តខាងនយោបាយ សំដៅបន្តអនុវត្តដំណើរការកែទម្រង់ ដោយឆន្ទៈមុតស្រួច ស្រុះដៃគ្នា ដោយដាក់ចេញនូវផែនការសកម្មភាព និងសហការតាមដានត្រួតពិនិត្យឲ្យមានភាពប្រទាក់ក្រឡាគ្នា ជាពិសេសផ្តោតលើភាពជាគំរូរបស់មន្ត្រីដឹកនាំ សមត្ថភាព និងមនសិការទទួលខុសត្រូវរបស់មន្ត្រីជំនាញ ការផ្សារភ្ជាប់រវាងថ្នាក់លើជាមួយថ្នាក់ក្រោម ការលុបបំបាត់អំពើពុករលួយ បក្ខពួកនិយម គ្រួសារនិយម ដើម្បីធានាសាមគ្គីភាព និងប្រសិទ្ធភាព តាមរយៈអភិក្រម "**ឆ្លុះកញ្ចក់ ងូតទឹក ដុះក្អែល ព្យាបាល និងវះកាត់**" ដើម្បីបង្កើនជំនឿ និងការគាំទ្ររបស់ប្រជាជនមកលើគណបក្ស។

## II-គោលការណ៍ និងលិខិតូបករណ៍មូលដ្ឋានសម្រាប់ការងារត្រួតពិនិត្យ

១.លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស

២.កម្មវិធីនយោបាយរបស់គណបក្ស សម្រាប់ការកសាង និងការពារមាតុភូមិឆ្នាំ២០១៨-២០២៣ អនុម័តដោយមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្ស ថ្ងៃទី១៩-២០-២១

ខែមករា ឆ្នាំ២០១៨ ដែលទាក់ទងនឹងការប្រឆាំងអំពើពុករលួយ និងបាតុភាពអសកម្ម៖

- ***ទំព័រទី១០***៖ រាំងស្កាត់រាល់ទម្រង់នៃការប្រើប្រាស់សិទ្ធិអំណាចបំពានច្បាប់ និទណ្ឌភាព និងអំពើហឹង្សាតាមគ្រប់រូបភាពក្នុងសង្គម។

- ***ទំព័រទី១១***៖ ពង្រឹងការអនុវត្តច្បាប់ និងលើកកម្ពស់សមត្ថភាពស្ថាប័នសាធារណៈគ្រប់ថ្នាក់ ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាជនគ្រប់មជ្ឈដ្ឋានឲ្យកាន់តែប្រសើរឡើង។

- ***ទំព័រទី១២***៖ គណបក្សប្រកាន់ជំហរម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយតាមរយៈការពង្រឹង និងការបង្កើនវិធានការស្នូលទាំង៣ គឺការអប់រំ ការបង្ការ និងទប់ស្កាត់ និងការបង្ក្រាបបទល្មើសបញ្ជូនទៅតុលាការ ដើម្បីជានាការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈគ្រប់យ៉ាងការពង្រឹងអភិបាលកិច្ចល្អ និងនីតិរដ្ឋ ព្រមទាំងរក្សាបាននូវភាពស្អាតស្អំ យុត្តិធម៌ និងកិត្តិយសរបស់មន្ត្រីសាធារណៈ។

៣.បាវចនា អភិក្រម និងអនុសាសន៍ដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្ស

- *ថ្ងៃក្នុងសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៤១ (ថ្ងៃទី១៨-១៩-២០ ខែធ្នូ ឆ្នាំ២០១៨)*៖

១. **បាវចនា ២ គឺ ៖** " ការធ្វើកំណែទម្រង់ខាងក្នុង និង បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ "

២. កំណែទម្រង់ស៊ីជម្រៅតាមរយៈ**អភិក្រម ៥ គឺ ៖** " ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ "បើកែទម្រង់ យើងរស់ ៩៩%

៣. សំណូមពរឲ្យមន្ត្រីយើងធ្វើសកម្មភាពបម្រើប្រជាជនទ្វេមួយជាពីរ

៤. ប្រជាជនបោះឆ្នោតទុកចិត្តយើង ឥឡូវយើងត្រូវបម្រើគាត់ឲ្យល្អ

៥. យុទ្ធសាស្ត្រកសាងកម្លាំងពិតរបស់បក្ស " រក្សាចាស់ កសាងថ្មី "។

- ***<u>ថ្ងៃងក្នុងពិធីបើកការដ្ឋានសាងសង់មន្ទីរពេទ្យមិត្តភាព កម្ពុជា-ចិន ត្បូងឃ្មុំ (ព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩)៖</u>***

"...មន្ត្រីរាជការណាដែលធ្វើអំពើផ្តេសផ្តាស ត្រូវតែទទួលនូវវិន័យដែលពួកគេនឹងត្រូវតែទទួលការបណ្តេញចេញ ឬអាចទទួលការផ្តន្ទាទោសធ្ងន់ធ្ងរជាងនេះដោយច្បាប់........ដែលខ្ញុំចាត់ទុកពេលនេះ **ខ្លាក៏វ៉ៃ ដំរីក៏វ៉ៃ ពស់ក៏វ៉ៃ កណ្តុរក៏វ៉ៃ កណ្តូបក៏វ៉ៃ រុយក៏វ៉ៃ វ៉ៃទាំងអស់ ឲ្យតែបំផ្លាញ និងរំខានដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ"។**

៤.ទិសដៅភារកិច្ចរបស់គណបក្ស (សម្រេចក្នុងសន្និបាតគណៈកម្មាធិការកណ្តាល លើកទី៤១ ថ្ងៃទី១៨-១៩-២០ ខែធ្នូ ឆ្នាំ ២០១៨)៖

-**<u>ទំព័រទី១៥៖</u>** (ភារកិច្ចជាយុទ្ធសាស្ត្រ)៖ បន្តកសាង ពង្រឹងគណបក្សឲ្យរឹងមាំទាំងខាងនយោបាយ សតិអារម្មណ៍ និង ចាត់តាំង ដើម្បីជានាការដឹកនាំសម្រេចរាល់ភារកិច្ចនយោបាយក្នុង ដំណាក់កាលថ្មីៗ យកចិត្តទុកដាក់គ្រប់គ្រង កសាង ពង្រឹងជួរមន្ត្រី គណបក្សឲ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទាំងសមត្ថភាពបំពេញ ការងារ ទាំងគុណធម៌ ដែលធានានូវការអនុវត្តគោលនយោបាយ របស់គណបក្សប្រកបដោយប្រសិទ្ធភាព ការផ្សារភ្ជាប់រវាងគណបក្ស និងមហាជន និងធានាដល់ការបន្តវេនៗ

-**<u>ទំព័រទី១៨</u>** <u>(ត្រេទី៣)</u>៖ ពង្រឹងការងារត្រួតពិនិត្យការ អនុវត្តកម្មវិធីនយោបាយ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងគោលការណ៍ នានារបស់គណបក្សៗ ពង្រឹងវិន័យអង្គការចាត់តាំងគណបក្ស មាន វិធានការម៉ឺងម៉ាត់ចំពោះអង្គការចាត់តាំង និងមន្ត្រី សមាជិកគណបក្ស ដែលប្រព្រឹត្តខុសឆ្គង និងការពារ លើកទឹកចិត្តដល់មន្ត្រីដែលមាន ស្នាដៃល្អៗ

**៥. សេចក្តីសម្រេច ស្តីពីការកែសម្រួលតួនាទី ភារកិច្ច សិទ្ធិអំណាច រចនាសម្ព័ន្ធ ចាត់តាំង និងរបៀបរបបធ្វើការរបស់ គណៈកម្មាធិការត្រួតពិនិត្យ៖**

- សេចក្ដីសម្រេចលេខ ១០២៥/១៥ សស.គក ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៥ របស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ស្ដីពីការកែសម្រួលតួនាទី ភារកិច្ច សិទ្ធិអំណាច រចនាសម្ព័ន្ធចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្ដាល។

- សេចក្ដីសម្រេចលេខ ១២៥៤/១៥ សស.គក ចុះថ្ងៃទី ១០ខែធ្នូឆ្នាំ២០១៥ របស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ស្ដីពីការកែសម្រួលភារកិច្ច សិទ្ធិអំណាច រចនាសម្ព័ន្ធចាត់តាំង និងរបៀបរបបធ្វើការ របស់គណៈកម្មាធិការត្រួតពិនិត្យគណបក្សក្រសួងស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៦. តួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ និងស្ថាប័នជំនួយការ។

៧. គោលការណ៍ពាក់ព័ន្ធនឹងគោលការណ៍ថ្មីៗទៀតរបស់គណបក្ស ដែលទាក់ទងនឹងការប្រឆាំងអំពើពុករលួយ និងបាតុភាពអសកម្ម។

## III-វិធីដំណើរការត្រួតពិនិត្យ

### ១.សមត្ថកិច្ច សិទ្ធិអំណាចត្រួតពិនិត្យ

-គណៈកម្មាធិការត្រួតពិនិត្យថ្នាក់នីមួយៗ គឺជាស្ថាប័នជំនួយការរបស់គណៈកម្មាធិការគណបក្សថ្នាក់ខ្លួនមានតួនាទី សិទ្ធិ

អំណាចនៅក្នុងវង្វង់ក្របខ័ណ្ឌជាសមត្ថកិច្ចទទួលខុសត្រូវ ដែលត្រូវបានគណៈកម្មាធិការគណបក្សថ្នាក់លើ និងថ្នាក់ខ្លួនផ្ទាល់ប្រគល់ឲ្យ។

**២.មុខសញ្ញាត្រួតពិនិត្យ**

- គណៈកម្មាធិការគណបក្សថ្នាក់ខ្លួនផ្ទាល់
- គណៈកម្មាធិការគណបក្សថ្នាក់ក្រោម
- អង្គការមូលដ្ឋានរបស់គណបក្ស
- មន្ត្រី និងសមាជិកគណបក្ស

**៣.ខ្លឹមសារត្រួតពិនិត្យ**

- គណៈកម្មាធិការត្រួតពិនិត្យថ្នាក់នីមួយៗ ត្រូវក្តាប់ជាប់នូវខ្លឹមសារជាគោលការណ៍របស់គណបក្ស និងត្រូវតាមដាន សិក្សាស្រាវជ្រាវពិនិត្យពិចារណា និងស្វែងរកនូវមុខសញ្ញាសកម្ម អសកម្ម និងប្រឆាំង។

**៤.ការស្នើសុំគោលការណ៍គណៈកម្មាធិការគណបក្ស**

-គណៈកម្មាធិការត្រួតពិនិត្យថ្នាក់នីមួយៗ ត្រូវប្រជុំពិភាក្សាឯកភាព និងអនុម័តដើម្បីស្នើសុំគោលការណ៍ដំណើរការត្រួតពិនិត្យពីគណៈកម្មាធិការគណបក្ស។

**៥.ការកសាងផែនការដើម្បីដំណើរការត្រួតពិនិត្យ**

-ត្រូវកំណត់ឲ្យច្បាស់ អំពីខ្លឹមសារ គោលបំណងសំណូមពរ មុខសញ្ញា គោលដៅ និងវិភាគលើសភាពការណ៍ទូទៅ ចំណុចខ្លាំង ចំណុចខ្សោយ និងឱកាស ដើម្បីធានាថាផែនការនេះអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព។

## ៦.ដំណាក់កាលនៃការអនុវត្តការត្រួតពិនិត្យ

*ក-សហការជាមួយអង្គការចាត់តាំងគណបក្ស ដែលពាក់ព័ន្ធនឹងមុខសញ្ញា*

*ខ-សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់*

*គ-ប្រមូលព័ត៌មានពីមន្ត្រី សមាជិកគណបក្ស ប្រជាពលរដ្ឋ អង្គការចាត់តាំងផ្សេងៗ ដែលពាក់ព័ន្ធ*

*ឃ-ជួបមុខសញ្ញាដែលត្រូវត្រួតពិនិត្យ (អង្គការចាត់តាំង មន្ត្រី ឬ សមាជិកគណបក្ស)។*

## ៧. ការបូកសរុប វាយតម្លៃ និងសន្និដ្ឋាន

*-វិភាគលើព័ត៌មាន និងភស្តុតាងដែលប្រមូលបាន រកឲ្យឃើញនូវគុណសម្បត្តិ គុណវិបត្តិ និងសំណូមពរផ្សេងៗ ហើយធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការងារត្រួតពិនិត្យ*

*-ប្រជុំគណៈកម្មាធិការត្រួតពិនិត្យ ដើម្បីធ្វើរបាយការណ៍វាយតម្លៃ សន្និដ្ឋាន និងលើកយោបល់ជូនគណៈកម្មាធិការគណបក្សថ្នាក់ខ្លួន*

*-កត់ត្រា និងរក្សាទុកនូវរាល់ឯកសារទាំងអស់ក្នុងសំណុំលិខិតផ្ទាល់របស់សាមីខ្លួន ឬសាមីអង្គការចាត់តាំងគណបក្ស។*

# ឯកសារ
# ស្ដីពីការងារត្រួតពិនិត្យអង្គការចាត់តាំង និងមន្ត្រី សមាជិកគណបក្ស ប្រព្រឹត្តល្មើសវិន័យរបស់គណបក្ស

## I-សេចក្ដីផ្ដើម

*ការងារត្រួតពិនិត្យរបស់គណបក្ស ជាការងារដ៏សំខាន់ចាំបាច់មិនអាចខ្វះបាន ក្នុងការងារដឹកនាំ កសាង និងពង្រឹងគណបក្ស ហើយក៏ជាការងាររបស់អង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ មន្ត្រី សមាជិកគណបក្សគ្រប់រូប និងគណបក្សទាំងមូល។*

*ការងារត្រួតពិនិត្យរបស់គណបក្ស គឺសំដៅរក្សាវិន័យរបស់គណបក្សឲ្យបានម៉ឺងម៉ាត់រកឲ្យឃើញនូវគុណសម្បត្តិ និងគុណវិបត្តិរបស់អង្គការចាត់តាំងគណបក្ស និងមន្ត្រី សមាជិកគណបក្ស ដើម្បីសន្និដ្ឋានវាយតម្លៃ លើកសរសើរ ឬដាក់វិន័យឲ្យបានត្រឹមត្រូវ និង យុត្តិធម៌។*

*ដើម្បីដឹកនាំគណបក្សឲ្យទទួលបានជ័យជម្នះ គឺគណបក្សមិនត្រឹមតែមានគោលនយោបាយត្រឹមត្រូវ មានគំនិតច្នៃប្រឌិត និងមានអង្គការចាត់តាំងរឹងមាំ មានវិធីសាស្ត្រដឹកនាំត្រឹមត្រូវប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវមានសមត្ថភាពក្នុងការចាត់តាំងអនុវត្តនិងមានការងារត្រួត*

ពិនិត្យគណបក្សយ៉ាងហ្មត់ចត់ និងទាន់ពេលវេលា។ ការងារត្រួតពិនិត្យគឺជាតួនាទីមួយក្នុងបណ្តាតួនាទីដឹកនាំសំខាន់ៗរបស់គណបក្សសំដៅរួមចំណែកធានាឲ្យការកំណត់នូវ គោលនយោបាយរបស់គណបក្សបានត្រឹមត្រូវ ជ្រួតជ្រាប និងជំរុញការអនុវត្តបានជោគជ័យព្រមទាំងកាត់បន្ថយ និងទប់ស្កាត់បាននូវរាល់ភាពអសកម្មរបស់អង្គការចាត់តាំងគណបក្ស និងមន្ត្រីសមាជិកគណបក្ស។

ទន្ទឹមនឹងនេះ ឆ្លងតាមការត្រួតពិនិត្យ ទើបរកឃើញការពិតដើម្បីធ្វើការស្តីបន្ទោស ដកតួនាទី និងបញ្ចេញពីគណបក្សបានទាន់ពេលវេលានូវជនឱកាសនិយម ដែលជ្រៀតចូលគណបក្ស ឬបំផ្លិចបំផ្លាញគណបក្ស ព្រមទាំងមន្ត្រី សមាជិកគណបក្សមិនគ្រប់លក្ខណៈសម្បត្តិ និងសមាជិកគណបក្សប្រែជាតុ ព្រមទាំងរកឃើញមន្ត្រី សមាជិកគណបក្សដែលល្អឆ្នើម ដើម្បីតែងតាំង ដំឡើងឋានៈ និងប្រគល់ភារកិច្ចសមស្រប ដែលធ្វើឲ្យអង្គការចាត់តាំងគណបក្ស និងមន្ត្រីសមាជិកគណបក្សកាន់តែរឹងមាំ និងស្អាតស្អំជានិច្ច។ ក្រៅពីនេះការងារត្រួតពិនិត្យក៏រកឃើញផងដែរ នូវអង្គការចាត់តាំងដែលល្អ ឬខ្សោយ ឬប្រព្រឹត្តកំហុសឆ្គងផ្សេងៗ ដើម្បីធ្វើការសរសើរ ជូនរង្វាន់ឬស្តីបន្ទោស ឬរំសាយនូវអង្គការចាត់តាំងនោះផងដែរ។

ម្យ៉ាងវិញទៀត គណបក្សយើងបាននឹងកំពុងកាន់អំណាចដូចនេះមន្ត្រី សមាជិកគណបក្សមានភារកិច្ចយ៉ាងសំខាន់ នៅក្នុងបណ្តាស្ថាប័នដឹកនាំរបស់គណបក្សគ្រប់លំដាប់ថ្នាក់។ ក្នុងលក្ខណៈ

នេះ ប្រសិនបើមន្ត្រី សមាជិកគណបក្ស មិនខិតខំបង្កើនសមត្ថភាពហាត់ពត់ លត់ដំបានល្អ និងមានការគ្រប់គ្រងត្រួតពិនិត្យឲ្យបានហ្មត់ចត់ទេនោះ គឺងាយនឹងមានការប្រព្រឹត្តខុសឆ្គងផ្សេងៗ ដូចជាអាត្មានិយម អសកម្មក្នុងការងារ គ្មានប្រជាធិបតេយ្យទូលំទូលាយ គាបសង្កត់ប្រជាជន លោភលន់ ស៊ីសំណូកសូកប៉ាន់ និងប្រព្រឹត្តកំហុសឆ្គងផ្សេងៗទៀត ដែលនឹងនាំក្តីអន្តរាយធ្ងន់ធ្ងរនូវទំនាក់ទំនងផ្ទៃក្នុងគណបក្ស ហើយងាយនឹងកើតឡើងនូវការបែងចែកបក្ខពួក បែកបាក់សាមគ្គីភាព ឯកភាពផ្ទៃក្នុង ដែលធ្វើឲ្យទំនាក់ទំនងរវាងគណបក្សនិងមហាជនត្រូវឃ្លាតឆ្ងាយពីគ្នា។ បញ្ហាខាងលើមានមូលហេតុរួមផ្សំជាច្រើន ដោយសារ (១)-មន្ត្រី សមាជិកគណបក្សខ្លួនឯងផ្ទាល់ (២)-ស្មារតីទទួលខុសត្រូវរបស់អង្គការចាត់តាំងដឹកនាំរបស់គណបក្ស (៣)-ការងារត្រួតពិនិត្យ និងអង្គការវិន័យរបស់គណបក្ស និងរដ្ឋមិនទាន់ដំណើរការបានល្អ និងជាប្រចាំ។

## II-អំពីវិន័យរបស់គណបក្ស

### ១.ទស្សនាទានអំពីវិន័យ

វិន័យរបស់អង្គការចាត់តាំងមួយ គឺជាសេចក្តីកំណត់គោលការណ៍ របៀបរបបនានា សំដៅបង្រួបបង្រួមមន្ត្រី សមាជិក និងផ្នែកនានា ក្នុងអង្គការចាត់តាំងគណបក្ស ឲ្យឯកភាពគ្នាជាធ្លុងមួយ ដើម្បីធ្វើសកម្មភាពតាមគោលបំណងរួម។ វិន័យ មានលក្ខណៈចាប់បង្ខំឲ្យមន្ត្រីសមាជិកនិងផ្នែកនានាក្នុងអង្គការចាត់តាំងគណបក្ស

ត្រូវគោរពតាម ដើម្បីរក្សាឲ្យអង្គការចាត់តាំងគណបក្សនោះ បានរឹងមាំ គង់វង្ស និងរីកចម្រើន។ ប្រសិនបើអង្គការចាត់តាំងគណបក្សណាមួយមានវិន័យធូររលុងនោះ គឺអង្គការចាត់តាំងនោះនឹងត្រូវទន់ខ្សោយខ្វះវិន័យ ហើយអង្គការចាត់តាំងនោះ ចៀសមិនផុតពីការបែកខ្ញែកបានឡើយ។ វិន័យរបស់គណបក្សបានកសាងឡើង ដោយឈរលើមូលដ្ឋាននៃកម្រិតភ្ញាក់រលឹកនយោបាយ និងកម្រិតភ្ញាក់រលឹករបស់មន្ត្រី សមាជិកគ្រប់រូប។

វិន័យរបស់គណបក្ស មានគោលបំណងរក្សាខ្ជាប់នូវការឯកភាព ទាំងខាងឆន្ទៈ និងសកម្មភាព ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការដឹកនាំ កសាង និងពង្រឹងគណបក្ស។ វិន័យរបស់គណបក្សត្រូវមានលក្ខណៈហ្មត់ចត់ និងស្វ័យភ្ញាក់រលឹក។ ដើម្បីមានការឯកភាពអំពីការចាត់តាំង ការឯកភាពអំពីឆន្ទៈ និងសកម្មភាព វិន័យរបស់គណបក្សមានចរិត ចាប់បង្ខំឲ្យមន្ត្រី សមាជិកគ្រប់រូប និងអង្គការចាត់តាំងគណបក្ស ត្រូវតែប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ នូវគោលការណ៍ប្រមូលផ្តុំប្រជាធិបតេយ្យ ប្រតិបត្តិដោយគ្មានលក្ខខណ្ឌនូវគោលនយោបាយ សេចក្តីសម្រេចចិត្ត សេចក្តីកំណត់ សេចក្តីណែនាំរបស់គណបក្ស។

មន្ត្រី សមាជិកគណបក្សគ្រប់រូប គប្បីយល់ថាដើម្បីសម្រេចបាននូវគោលបំណង និងឧត្តមគតិរបស់គណបក្ស គឺមន្ត្រី សមាជិកគណបក្សគ្រប់រូប ត្រូវតែប្រតិបត្តិដោយម៉ឺងម៉ាត់នូវលក្ខន្តិកៈ បទបញ្ជា

ផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និង សេចក្ដីសម្រេចចិត្តនានារបស់គណបក្ស នោះគឺដោយសារតែផលប្រយោជន៍រួមរបស់ជាតិ គណបក្ស ប្រជាជន សាមីខ្លួន និងគ្រួសារខ្លួន ទោះបីជាស្ថិតក្នុងស្ថានភាពណាក៏ដោយ។

## ២.ខ្លឹមសារនៃវិន័យ

ខ្លឹមសារសំខាន់នៃការបង្កើតវិន័យ គឺដើម្បីធានាឲ្យគោលនយោបាយរបស់គណបក្ស បទប្បញ្ញត្តិនានា នៃជីវភាពគណបក្ស និងច្បាប់របស់រដ្ឋ ត្រូវបានអនុវត្តជាដាច់ខាត។ ការបង្កើតវិន័យរបស់គណបក្ស គឺមិនមែនជាការដាក់វិន័យឲ្យបានច្រើននោះទេ ប៉ុន្តែសំខាន់ គឺបង្កើនស្មារតីភ្ញាក់រលឹកក្នុងការប្រតិបត្តិវិន័យយ៉ាងម៉ឺងម៉ាត់ មនសិការ គោរព អង្គការវិន័យ។ ប៉ុន្តែប្រសិនបើមន្ត្រី សមាជិក ឬអង្គការចាត់តាំងគណបក្ស ប្រព្រឹត្តខុសធ្ងន់ដល់កម្រិតត្រូវដាក់វិន័យនោះគឺត្រូវតែដាក់វិន័យ ដើម្បីបង្កើនជំនឿ និងរក្សាវិន័យរបស់គណបក្សឲ្យបានម៉ឺងម៉ាត់។

កំហុសខាងវិន័យ គឺជាការកើតឡើងពីការប្រព្រឹត្តដោយចេតនា ឬអចេតនា ការខកខានមិនបានអនុវត្តការភ្លេចភ្លាំង ការធ្វេសប្រហែស ការខ្ជីខ្ជា និងរាល់ការបំពានទៅ លើលក្ខន្តិក: បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និង សេចក្ដីសម្រេចចិត្តនានារបស់គណបក្ស។ អង្គការចាត់តាំង និងមន្ត្រី

សមាជិកគណបក្ស ដែលប្រព្រឹត្តល្មើសខុសឆ្គង ត្រូវទទួលវិន័យធ្ងន់ ឬស្រាល ទៅតាមកម្រិតនៃខ្លឹមសារខុសឆ្គង។

## ៣.ទិសដៅនៃការដាក់វិន័យ

ដើម្បីធានាឲ្យការដាក់វិន័យរបស់គណបក្ស សម្រេចបានតាមគោលបំណង ដោយទទួលបានលទ្ធផលខ្ពស់ និងមានប្រសិទ្ធភាព គឺត្រូវកំណត់ទិសដៅនៃការដាក់វិន័យឲ្យបានត្រឹមត្រូវ។ ការកំណត់ទិសដៅនៃការដាក់វិន័យ មិនមែនផ្អែកលើចំនួនបទល្មើសខុសឆ្គងទេ តែសំខាន់ត្រូវផ្អែកលើចរិតលក្ខណៈ និងភាពអន្តរាយនៃអំពើខុសឆ្គង សំដៅបម្រើឲ្យភារកិច្ចនយោបាយ ការងារដឹកនាំ កសាង និងពង្រឹងគណបក្ស។

សកម្មភាពទាំងឡាយដែលខ្វះស្មារតីទទួលខុសត្រូវ គ្មានការប្រុងប្រយ័ត្នចំពោះ កម្លាំងអមិត្ត បង្កបង្កើតបក្ខពួក បំបែកបំបាក់សាមគ្គីភាព ឯកភាពផ្ទៃក្នុង ផ្តាច់ការ គំរាម កំហែងមហាជន ប្រព្រឹត្តអំពើពាលាអាវ៉ាសែ លោភលន់ ស៊ីសំណូកសូកប៉ាន់ ល្មើសច្បាប់ គឺជាកំហុសឆ្គងយ៉ាងធ្ងន់ធ្ងរដែលត្រូវតែដាក់វិន័យឲ្យសមស្រប។ ចំពោះកង្វះខាតធម្មតាខាងផ្នែកឥរិយាបថ ខាងផ្នែកជីវភាពគណបក្ស ក៏ត្រូវយកចិត្តទុកដាក់ជួយកែលម្អ ហើយក្នុងករណីចាំបាច់ ក៏ត្រូវមានរូបភាពវិន័យសមស្របផងដែរ។

## ៤.លក្ខខណ្ឌនៃការដាក់វិន័យ

*ការដាក់វិន័យ ត្រូវតែមាន " ភាពយុត្តិធម៌ ច្បាស់លាស់ពិតប្រាកដ និងទាន់ពេលវេលា "។*

*-**យុត្តិធម៌** ៖ គឺមន្ត្រី សមាជិកគណបក្សគ្រប់រូប ត្រូវតែប្រតិបត្តិយ៉ាងម៉ឺងម៉ាត់នូវវិន័យរបស់គណបក្ស។ មន្ត្រី សមាជិកគណបក្សណា បំពានវិន័យរបស់គណបក្ស សុទ្ធតែត្រូវបានត្រួតពិនិត្យឲ្យបានច្បាស់លាស់ ដើម្បីអប់រំ ហើយប្រសិនបើឃើញថា គួរត្រូវដាក់វិន័យនោះ គឺមិនត្រូវយកលេសអ្វី ដើម្បីរំលងចោលឡើយ។ ការដាក់វិន័យត្រូវស្មើភាព មិនលម្អៀង ព្រោះក្នុងគណបក្សសមាជិកគ្រប់រូប សុទ្ធតែមានភាពស្មើគ្នាអំពីនយោបាយ ម៉្លោះហើយ ការដាក់វិន័យ គឺមិនបានបែងចែក ប្រកាន់អំពីតួនាទីខ្ពស់ ឬទាប អតីតភាពក្នុងគណបក្សយូរ ឬឆាប់ឡើយ។ គ្មានមន្ត្រី សមាជិកណាម្នាក់មានអភ័យឯកសិទ្ធិ ហើយក៏គ្មានមន្ត្រី សមាជិកណាមួយបានចាត់ទុកខ្លួនស្ថិតនៅក្នុងករណីពិសេសឡើយ។ មន្ត្រី សមាជិក ដែលកាន់តួនាទីខ្ពស់ គឺបានលត់ដំយូរឆ្នាំក្នុងគណបក្សរួចហើយ ដូចនេះបើប្រព្រឹត្តខុស វិន័យ គឺកាន់តែត្រូវដាក់វិន័យយ៉ាងម៉ឺងម៉ាត់។*

*-**ច្បាស់លាស់ពិតប្រាកដ** ៖ គឺជាការដាក់វិន័យត្រូវឲ្យចំអ្នកប្រព្រឹត្តខុសឆ្គង ត្រូវឲ្យចំចរិត និងកម្រិតអន្តរាយ មូលហេតុនៃការខុសឆ្គង ចរិតលក្ខណៈ និងកាលៈទេសៈ ដែលការខុសឆ្គងបានកើតឡើង។ ដើម្បីឲ្យការដាក់វិន័យបានច្បាស់លាស់ពិតប្រាកដមុន*

ពេលសម្រេចដាក់វិន័យ គឺត្រូវស្រាវជ្រាវ ពិនិត្យវិនិច្ឆ័យឲ្យបានហ្មត់ចត់ គ្រប់គ្រាន់ សមហេតុផល។ ត្រូវផ្អែកលើភស្តុតាងជាក់ស្តែង ត្រូវថ្លឹងថ្លែងលើផ្នែកជាច្រើន ត្រូវបែងចែកច្បាស់លាស់រវាងអត្តចរិត និងធាតុភាពចរិតខុសឆ្គង ស្ថិតនៅលើផ្នែកនយោបាយ ឬស្ថិតនៅក្នុងឥរិយាបថជីវភាពរស់នៅ ការខុសឆ្គងនេះកើតឡើងដោយសារកម្រិតយល់ដឹងទាប ឬការខុសឆ្គងដោយអចេតនា ខុសឆ្គងលើកដំបូង ឬជាច្រើនលើកមកហើយ កម្រិតនៃភាពអន្តរាយតិច ឬច្រើន ការទទួលខុសត្រូវ សំខាន់ស្ថិតលើបុគ្គលដែលជាមន្ត្រី សមាជិកគណបក្ស ឬរបស់សមូហភាព។ ទន្ទឹមនឹងនេះ ត្រូវមានការថ្លឹងថ្លែងរវាងការខុសឆ្គង គុណវិបត្តិ ស្នាដៃ អាកប្បកិរិយាទទួលស្គាល់ការខុសឆ្គងរបស់មន្ត្រី សមាជិកគណបក្ស។

-**ទាន់ពេលវេលា ៖** ការដាក់វិន័យ ត្រូវបានអនុវត្តចំពេលចំទីកន្លែង ជាបន្ទាន់ដោយមិនត្រូវទុកឲ្យយឺតយ៉ាវ ឬពន្យាពេល ដែលនាំឲ្យប៉ះពាល់ដល់ប្រសិទ្ធភាពក្នុងការអប់រំមន្ត្រី សមាជិក និងអង្គការចាត់តាំងគណបក្ស ដែលបានប្រព្រឹត្តខុសឆ្គង និងប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តភារកិច្ចនយោបាយ ការងារកសាង និងពង្រឹងគណបក្សឡើយ។ លើសពីនេះ ការដាក់វិន័យទាន់ពេលវេលាក៏ជាការដាស់តឿនមន្ត្រី សមាជិកដទៃទៀត នៅក្នុងអង្គភាពនោះ មិនឲ្យធ្លាក់ខ្លួនខុសឆ្គងដូចគ្នាទៀតផងដែរ។

បើចង់ដាក់វិន័យឲ្យបានទាន់ពេលវេលា គឺត្រូវគ្រប់គ្រងមន្ត្រី សមាជិកគណបក្សឲ្យបានហ្មត់ចត់ ត្រូវមានការចាត់តាំងល្អក្តាប់សភាពការណ៍របស់មន្ត្រី សមាជិក អង្គការចាត់តាំង ប្រតិបត្តិវិន័យរបស់គណបក្ស ហើយពេលដឹងថាមន្ត្រី សមាជិក ឬអង្គការចាត់តាំងគណបក្សណាបំពានវិន័យនោះ គឺត្រូវពិនិត្យវិនិច្ឆ័យឲ្យបានច្បាស់លាស់ពិតប្រាកដ និងទាន់ពេលវេលា។ ក្រោយពីអង្គការមានសមត្ថកិច្ចបានពិនិត្យវិនិច្ឆ័យ និងកំណត់រូបភាព វិន័យរួចហើយនោះ គឺត្រូវចេញសេចក្តីសម្រេចចិត្ត ស្តីពីការដាក់វិន័យ ហើយប្រកាសភ្លាមដោយមិនត្រូវពន្យាពេលដោយមូលហេតុណាមួយឡើយ។

**៥.ទម្រង់បែបបទនៃការដាក់វិន័យ**

ទម្រង់បែបបទនៃការដាក់វិន័យ គឺជាការកំណត់ជាក់ស្តែង ដែលបង្ខំឲ្យរាល់អង្គការចាត់តាំង និងមន្ត្រី សមាជិកគណបក្សត្រូវតែគោរពតាម សំដៅធានាឲ្យការដាក់វិន័យបានម៉ឺងម៉ាត់។ ទម្រង់បែបបទនៃការដាក់វិន័យ គឺត្រូវគោរពតាមរូបភាពវិន័យ ការដាក់វិន័យ និងសមត្ថកិច្ចដាក់វិន័យ ត្រូវបានអនុវត្តស្របតាមច្បាប់របស់រដ្ឋលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងគណបក្ស និងការកំណត់ផ្សេងៗទៀតរបស់គណបក្ស។ ដើម្បីក្តាប់ជាប់ និងបំពេញបានល្អនូវកិច្ចការមួយចំនួនស្របតាមទម្រង់បែបបទនៃការដាក់វិន័យ យើងត្រូវធ្វើដូចតទៅៈ

## ក.ការទទួលខុសត្រូវចំពោះសាខាគណបក្ស

មន្ត្រី សមាជិកគណបក្សគ្រប់រូប គិតទាំងមន្ត្រី សមាជិកគណៈកម្មាធិការគណបក្សដែលប្រព្រឹត្តខុសឆ្គង ត្រូវទទួលការដាក់វិន័យ គឺត្រូវបានធ្វើការត្រួតពិនិត្យចំពោះមុខសាខាគណបក្ស។ មន្ត្រី សមាជិកគណបក្ស ត្រូវបរិយាយពីកំហុសរបស់ខ្លួន ដោយស្មារតីភ្ញាក់រលឹក និងកំណត់រូបភាពវិន័យមួយសម្រាប់ខ្លួន ហើយមានសិទ្ធិអនុម័តអំពីរូបភាពវិន័យចំពោះខ្លួន ពេលដែលសាខាគណបក្សសម្រេចដាក់វិន័យ។

សាខាគណបក្សពិនិត្យ សន្និដ្ឋាន និងសម្រេចដាក់រូបភាពវិន័យមួយសមស្របទៅនឹងទោសកំហុសរបស់មន្ត្រី សមាជិកគណបក្ស តាមសមត្ថកិច្ចរបស់ខ្លួន ឬស្នើឡើងថ្នាក់លើដែលមានសមត្ថកិច្ចពិនិត្យ សម្រេច។ ករណីដែលមន្ត្រី សមាជិកគណបក្ស ជាមន្ត្រី សមាជិកគណៈកម្មាធិការគណបក្ស ឬជាមន្ត្រីដែលថ្នាក់លើគ្រប់គ្រងប្រព្រឹត្តខុសឆ្គង (មិនស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់សាខាគណបក្ស) គឺត្រូវលើកយកទៅត្រួតពិនិត្យចំពោះមុខគណៈកម្មាធិការគណបក្ស ឬអង្គការចាត់តាំងគណបក្ស ដែលមានសមត្ថកិច្ច។ ក្រោយពីមានសេចក្តីសម្រេចដាក់វិន័យ គឺអង្គការចាត់តាំងគណបក្សថ្នាក់លើ នឹងជូនដំណឹងឲ្យសាខាគណបក្ស ឬមន្ត្រី សមាជិកគណបក្សនោះបានជ្រាប។

## ខ.ការវាយតម្លៃកំហុស និងវិន័យ

*អង្គការចាត់តាំងគណបក្ស មានសមត្ថកិច្ចត្រូវតែធ្វើយ៉ាងម៉ឺងម៉ាត់ ត្រូវតែពិនិត្យ ពិចារណា ដោយហ្មត់ចត់ ត្រូវផ្អែកលើកស្តុតាងជាក់ស្តែង។ មុនពេលសម្រេចដាក់វិន័យ គឺត្រូវតែផ្ចិតផ្ចង់ស្តាប់យោបល់របស់អ្នកល្មើសវិន័យ ឬតំណាងរបស់អង្គការចាត់តាំងគណបក្សជាមុនសិន។ ត្រូវវាយតម្លៃត្រឹមត្រូវនូវលក្ខណៈចរិតនៃភាពអន្តរាយ និងមូលហេតុនៃ ការខុសឆ្គង ដើម្បីកំណត់រូបភាពដាក់វិន័យឲ្យបានសមស្រប។ សេចក្តីសម្រេចដាក់វិន័យ ត្រូវពន្យល់ឲ្យអ្នកល្មើសវិន័យ ឬអង្គការចាត់តាំងគណបក្សបានដឹង។ អ្នកទទួលវិន័យ ឬ អង្គការចាត់តាំងគណបក្ស មានសិទ្ធិបញ្ចេញយោបល់របស់ខ្លួន។*

## គ.សិទ្ធិរបស់មន្ត្រី សមាជិក និងអង្គការចាត់តាំងគណបក្សទទួលរងវិន័យ

*ដើម្បីជានាដោះស្រាយឲ្យបានល្អ ចំពោះសិទ្ធិទាំងឡាយរបស់មន្ត្រី សមាជិក និង អង្គការចាត់តាំងគណបក្ស ដែលត្រូវទទួលរងវិន័យ ៖*

*-មន្ត្រី សមាជិក ឬអង្គការចាត់តាំងគណបក្ស ដែលត្រូវទទួលរងវិន័យរបស់គណបក្ស មានសិទ្ធិតវ៉ា និងសំណូមពរឲ្យពិនិត្យវិនិច្ឆ័យឡើងវិញ ប្រសិនបើខ្លួនមិនយល់ព្រម លើសេចក្តីសម្រេចដាក់វិន័យ ហើយអាចតវ៉ាឡើងថ្នាក់លើទៀត រហូតដល់គណៈកម្មាធិការកណ្តាលគណបក្ស។*

-ក្នុងករណីគណៈកម្មាធិការគណបក្សមានសមត្ថកិច្ច មិនទាន់បានសម្រេចយល់ព្រមលើសេចក្ដីសម្រេចបញ្ចេញ ឬរំសាយអង្គការចាត់តាំងគណបក្សមួយ បុគ្គល និងអង្គការចាត់តាំងគណបក្សទទួលរងវិន័យនោះ នៅតែមានសិទ្ធិធ្វើសកម្មភាពដដែល។

-ក្នុងករណីដែលមន្ត្រី សមាជិក ត្រូវប្ដឹងទៅតុលាការ គឺអង្គការចាត់តាំងគណបក្សមានសមត្ថកិច្ច ត្រូវដំណើរការដាក់វិន័យខាងគណបក្សឲ្យបានទាន់ពេលវេលា ឬបើមន្ត្រី សមាជិកគណបក្សល្មើសច្បាប់រដ្ឋ ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារនោះ ក្នុងករណីមិនទាន់មានការដាក់វិន័យ អាចផ្អាកជីវភាពគណបក្សបណ្ដោះអាសន្នសិន។

-ការផ្អាកជីវភាពគណបក្ស និងសកម្មភាពជាបណ្ដោះអាសន្នរបស់មន្ត្រី សមាជិក និងអង្គការចាត់តាំងគណបក្សមួយ ត្រូវបានអនុវត្តតែក្នុងករណីពិសេសប៉ុណ្ណោះ ដូចជារឿងក្ដីកំពុងស្ថិតក្នុងនីតិវិធីតុលាការ និងចំពោះអង្គការចាត់តាំងគណបក្ស ដែលប្រឈមវិន័យរំសាយនោះ។ រយៈពេលផ្អាកជាបណ្ដោះអាសន្នមិនឲ្យលើសពី៦ខែ និងអាចពន្យាបានយូរបំផុត មិនឲ្យលើសពី៦ខែទៀតឡើយ។ ក្នុងរយៈពេលផ្អាកបណ្ដោះអាសន្ន គឺអង្គការចាត់តាំងគណបក្សដែលមានសមត្ថកិច្ចត្រួតពិនិត្យ ត្រូវធ្វើការពិនិត្យវិនិច្ឆ័យ ពិចារណាជាបន្ទាន់ ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ និងទាន់ពេលវេលា ដោយមិនទុកឲ្យហួសរយៈពេលផ្អាកជាបណ្ដោះអាសន្ន។ ប្រសិនបើការ

ខុសឆ្គងមិនដល់កម្រិតបញ្ចេញពីសមាជិក ឬត្រូវរំសាយអង្គការចាត់តាំងគណបក្សនោះ គឺត្រូវមានសេចក្តីសម្រេចដើម្បីទុកឲ្យមន្ត្រី សមាជិក ឬអង្គការចាត់តាំងគណបក្សនោះ បន្តជីវភាពគណបក្ស និង សកម្មភាព។

-បើពិនិត្យឃើញមានករណីណា ដែលការដាក់វិន័យ មានភាពខុសឆ្គង គឺត្រូវម្ចាស់ការ កែឡើងវិញ និងត្រូវតែបំភ្លឺឲ្យបានច្បាស់លាស់ ហើយត្រូវរក្សាទុកនូវរាល់សិទ្ធិដ៏សមស្របរបស់មន្ត្រី សមាជិកគណបក្សនោះ។ ចំពោះករណីទាំងឡាយដែលវិនិច្ឆ័យខុសឆ្គងដោយចេតនា ហើយមិនព្រមកែ មិនបំភ្លឺឡើងវិញ មិនរក្សាទុកនូវរាល់សិទ្ធិសមស្របរបស់មន្ត្រី សមាជិកគណបក្សនោះ ឬការពារបិទបាំងនូវរាល់អំពើប្រព្រឹត្តល្មើសលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងគណបក្ស ច្បាប់របស់រដ្ឋ លក្ខណៈសម្បត្តិមន្ត្រី សមាជិកគណបក្ស ដោយចេតនា គឺសុទ្ធតែត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ និងត្រូវដាក់វិន័យដោយសមស្របចំពោះបុគ្គល ឬអង្គការចាត់តាំងគណបក្ស ដែលបានសម្រេចដាក់វិន័យមានភាពខុសឆ្គងនោះ។

### ៦.រូបភាពវិន័យ និងការដាក់វិន័យ

អង្គការចាត់តាំង និងមន្ត្រី សមាជិកគណបក្ស ដែលប្រព្រឹត្តល្មើសខុសឆ្គងត្រូវទទួលវិន័យធ្ងន់ ឬស្រាល ទៅតាមកម្រិតនៃខ្លឹមសារខុសឆ្គង។

### ក.រូបភាពវិន័យ

*អង្គការចាត់តាំង និងមន្ត្រី សមាជិកគណបក្ស ដែលប្រព្រឹត្តល្មើសខុសឆ្គង ត្រូវទទួលវិន័យធ្ងន់ ឬស្រាល តាមរូបភាពដូចខាងក្រោម៖*[1]

*- ចំពោះអង្គការចាត់តាំងគណបក្ស ៖* ***ស្តីបន្ទោស និងរំសាយ***

*- ចំពោះសមាជិក ៖* ***ស្តីបន្ទោស ដកតួនាទី និងបញ្ចេញពីសមាជិក។***

**ខ.ការដាក់វិន័យ** *(យោងបទបញ្ជាផ្ទៃក្នុងគណបក្ស ជំពូកX ប្រការ៣០)*

***ចំពោះអង្គការចាត់តាំងគណបក្ស***

***-រូបភាពស្តីបន្ទោស*** *គឺត្រូវអនុវត្តចំពោះអង្គការចាត់តាំងគណបក្ស ដែលបានប្រព្រឹត្តខុសឆ្គងក្នុងការអនុវត្តភារកិច្ច និងសិទ្ធិរបស់ខ្លួន ប៉ុន្តែមិនបណ្តាលឲ្យប៉ះពាល់ ឬប៉ះពាល់តិចតួច ដែលមិនជះឥទ្ធិពលខ្លាំងដល់ផលប្រយោជន៍របស់គណបក្ស។*

***-រូបភាពរំសាយ*** *ត្រូវអនុវត្តចំពោះអង្គការចាត់តាំងគណបក្ស ដែលមានគុណវិបត្តិធ្ងន់ធ្ងរ ស្ថិតក្នុងករណីណាមួយ ក្នុងចំណោមករណីទាំង២ ខាងក្រោម ៖*

---

[1]លក្ខន្តិកៈគណបក្សជំពូក IX មាត្រាទី ២៥

• មានសមាជិកគណបក្សចាប់ពី ២ភាគ៣ ឡើងទៅ (ចំពោះសាខាគណបក្ស) ឬ២ភាគ៣ នៃចំនួនសមាជិកគណៈកម្មាធិការគណបក្ស ដែលប្រព្រឹត្តខុសធ្ងន់ដល់កម្រិតត្រូវដាក់វិន័យបញ្ចេញពីសមាជិក។

• សមូហភាពក្នុងអង្គការចាត់តាំងគណបក្សនោះ មានសកម្មភាពប្រឆាំងនឹងគោលនយោបាយរបស់គណបក្ស ដោយចេតនា ឬមានភស្តុតាងបញ្ជាក់ថា លែងមានជំនឿ ទុកចិត្តខាងនយោបាយចំពោះគណបក្ស។

អង្គការចាត់តាំងគណបក្សណាមួយ ត្រូវទទួលការដាក់វិន័យ ពេលដែលអង្គការចាត់តាំងនោះមានការខុសធ្ងន់អំពីភារកិច្ច និងការទទួលខុសត្រូវក្នុងការងារ គឺចាំបាច់ត្រូវកំណត់ឲ្យច្បាស់នូវការទទួលខុសត្រូវនោះ តើស្ថិតក្នុងក្របខ័ណ្ឌណា តើជាកំហុសរបស់គណៈអចិន្ត្រៃយ៍ ឬគណៈកម្មាធិការគណបក្ស ឬអង្គការចាត់តាំងនោះទាំងមូល ដើម្បីមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការពិនិត្យ វិនិច្ឆ័យដាក់វិន័យឲ្យបានត្រឹមត្រូវ។

-មន្ត្រី សមាជិក ឬអង្គការចាត់តាំងគណបក្ស ដែលត្រូវទទួលការត្រួតពិនិត្យដាក់វិន័យ មានសិទ្ធិធ្វើការបញ្ជាក់បំភ្លឺការពារខ្លួននៅចំពោះមុខសមត្ថកិច្ចដាក់វិន័យ។ ក្នុងករណីមិនសុខចិត្តចំពោះរូបភាពវិន័យដែលត្រូវទទួល មន្ត្រី សមាជិក ឬអង្គការចាត់តាំងគណបក្សនោះ មានសិទ្ធិតវ៉ាឡើងទៅគណបក្សថ្នាក់លើ។

## ចំពោះមន្ត្រី សមាជិកគណបក្ស

គុណភាពរបស់មន្ត្រី សមាជិកគណបក្ស គឺជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ៗ ផ្សេងៗទៀត ដូច្នេះការកសាងមន្ត្រី សមាជិកគណបក្សឲ្យមានគុណភាព គឺជាការងារមួយយ៉ាងសំខាន់របស់អង្គការចាត់តាំងគណបក្ស ហើយក៏ជាមូលដ្ឋានមួយ ដើម្បីដឹកនាំកសាង គណបក្សឲ្យរឹងមាំ និងធានាបាននូវរាល់ការបំពេញសកម្មភាពប្រកបដោយប្រសិទ្ធភាពរបស់បណ្ដាអង្គការចាត់តាំងគណបក្ស។ កន្លងមកគណបក្សយើងបានជ្រើសរើស និងហាត់ពត់ លត់ដំ បាននូវជួរមន្ត្រីដឹកនាំបង្គោល និងមន្ត្រី សមាជិកគណបក្ស ដែលមានគុណភាព ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ នូវគោលនយោបាយរបស់គណបក្ស គោរពវិន័យបានល្អព្រមទាំងបង្កើតបាននូវស្នាដៃយ៉ាងច្រើនគួរឲ្យកត់ថថសម្គាល់។

ការងារត្រួតពិនិត្យមន្ត្រី សមាជិកគណក្សល្មើសខុសឆ្គង គឺពុំមែនត្រឹមតែជម្នះនូវភាពអសកម្ម ចំណុចខ្សោយ នៅក្នុងគណបក្សប៉ុណ្ណោះទេ គឺថែមទាំងលើកកម្ពស់ស្មារតីប្រុងប្រយ័ត្ន ភ្ញាក់រលឹករបស់មន្ត្រី សមាជិកគណបក្ស ចំពោះការប្រតិបត្តិនូវលក្ខន្តិកៈគណបក្ស វិន័យរបស់គណបក្ស សំដៅការពារមន្ត្រី សមាជិក ព្រមទាំងបញ្ចេញពីគណបក្សនូវសមាសភាពអាក្រក់ ឱកាសនិយម និងសមាសភាពអមិត្ត ដែលជ្រៀតចូលគណបក្សដើម្បីបំផ្លាញគណបក្ស

ពោលគឺ ដើម្បីរួមចំណែកដឹកនាំ កសាង និងពង្រឹងអង្គការចាត់តាំងគណបក្សឲ្យស្អាតស្អំរឹងមាំ។

-**ស្តីបន្ទោស** ជារូបភាពវិន័យទាបបំផុត ដោយអនុវត្តចំពោះករណីទាំងឡាយដែលមន្ត្រី សមាជិកគណបក្ស មានកំហុសខ្វះខាត ហើយការដាក់វិន័យនោះ គឺដើម្បីអប់រំឲ្យបានប្រសើរឡើង។ រូបភាពស្តីបន្ទោស គឺត្រូវអនុវត្តចំពោះមន្ត្រី សមាជិក ឬអង្គការចាត់តាំងគណបក្ស ដែលបានប្រព្រឹត្តខុសឆ្គងក្នុងការអនុវត្ត ភារកិច្ច និងសិទ្ធិរបស់ខ្លួន ប៉ុន្តែមិនបណ្តាលឲ្យប៉ះពាល់ ឬប៉ះពាល់តិចតួចដែលមិនជះឥទ្ធិពលខ្លាំងដល់ផលប្រយោជន៍គណបក្ស។

-**ដកតួនាទី** ជារូបភាពវិន័យធ្ងន់បង្គួររបស់គណបក្ស។ មន្ត្រីសមាជិកដែលកំពុង កាន់តួនាទីក្នុងគណបក្ស ដែលប្រព្រឹត្តខុសឆ្គងធ្ងន់បង្គួរ ឬធ្លាប់បានទទួលការស្តីបន្ទោសច្រើនដង តែមិនព្រមកែហើយពិនិត្យឃើញថា មិនស័ក្តសមដើម្បីកាន់តួនាទីនោះទៀត គឺត្រូវអនុវត្តរូបភាពវិន័យដកតួនាទី។ នៅពេលអនុវត្តវិន័យដោយរូបភាពដកតួនាទីចំពោះមន្ត្រី សមាជិកគណបក្សមួយរូប ដែលកាន់តួនាទីច្រើន គឺត្រូវយោងទៅតាមកម្រិតចរិតលក្ខណៈនៃបទល្មើស និងឥទ្ធិពលនៃបទល្មើសខុសឆ្គង ដើម្បីធ្វើការសម្រេចដកតួនាទីមួយ ឬដកតួនាទីច្រើន ឬដកតួនាទីទាំងអស់ក្នុងគ្រាតែមួយ ហើយអង្គការចាត់តាំងគណបក្សដែលមានសមត្ថកិច្ចដកតួនាទី ជាអ្នកចេញសេចក្តីសម្រេចចិត្ត។

ក្នុងករណីដែលប្រធាន អនុប្រធាន សមាជិក គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការ គណបក្ស បានប្រព្រឹត្តខុសឆ្គង ហើយត្រូវដកតួនាទី គឺបុគ្គលនោះ នៅតែជាសមាជិកគណៈកម្មាធិការគណបក្ស។ ប្រសិនបើពិនិត្យឃើញថា បុគ្គលនោះ មិនស័ក្តិសមទុកក្នុងគណៈ កម្មាធិការគណបក្សទៀតនោះ គឺត្រូវដកតួនាទីពីសមាជិកគណៈកម្មាធិការគណបក្សថែមទៀត។

**-បញ្ចេញពីសមាជិក** គឺជារូបភាពវិន័យខ្ពស់បំផុត ហើយត្រូវអនុវត្តចំពោះមន្ត្រី សមាជិកគណបក្សណាដែលបានប្រព្រឹត្តខុសឆ្គងធ្ងន់ធ្ងរ ហើយពិនិត្យឃើញថា ពុំមានលក្ខណសម្បត្តិជាសមាជិកគណបក្សទៀតឡើយ។ ការសម្រេចបញ្ចេញសមាជិកពីគណបក្ស នាំមកនូវការបញ្ចប់អាណត្តិរបស់សមាជិកនោះ នៅក្នុងរាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា និងក្រុមប្រឹក្សានានា ដែលគេបានទទួលពីគណបក្ស។

គណបក្សមិនអនុវត្តរូបភាពបញ្ចេញពីសមាជិកគណបក្សជាស្ថាពរឡើយ។ សមាជិក គណបក្ស ថ្វីបើត្រូវបានដាក់វិន័យបញ្ចេញពីសមាជិកគណបក្ស ប៉ុន្តែក្រោយមក ប្រសិនបើបុគ្គលនោះបានកែខ្លួន និងមានគ្រប់លក្ខណៈសម្បត្តិជាសមាជិកគណបក្ស គឺបុគ្គលនោះនៅតែអាចបញ្ចូលជាសមាជិកគណបក្សឡើងវិញ។ ក្នុងករណីដែលសមាជិកគណបក្សត្រូវបានប្ដឹងដោយប្រព្រឹត្តខុសនឹងច្បាប់រដ្ឋ ហើយត្រូវបានតុលាការឃុំខ្លួន ឬត្រូវបានតុលាការផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារ

គឺអង្គការចាត់តាំងគណបក្សដែលមានសមត្ថកិច្ច ត្រូវតែពិនិត្យវិនិច្ឆ័យជាបន្ទាន់។

សេចក្ដីសម្រេចដាក់វិន័យ ត្រូវកត់ត្រាទុកក្នុងសំណុំឯកសារផ្ទាល់របស់មន្ត្រី សមាជិកគណបក្ស និងសមាជិកគ្រប់រូបនៃអង្គការចាត់តាំងគណបក្សដែលត្រូវទទួលវិន័យ។

**គ.មុខសញ្ញាត្រួតពិនិត្យ**

គណៈកម្មាធិការត្រួតពិនិត្យ មានភារកិច្ចត្រួតពិនិត្យអង្គការចាត់តាំងគណបក្ស និងមន្ត្រីសមាជិកគណបក្ស ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគណបក្សថ្នាក់ខ្លួន។

ចំពោះមន្ត្រីគណបក្សដែលមានឋានៈតួនាទីអាស្រ័យដោយថ្នាក់លើគ្រប់គ្រងនោះត្រូវរាយការណ៍ ជូនគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការគណបក្សថ្នាក់លើពិនិត្យពិចារណា តើគួរធ្វើការត្រួតពិនិត្យ ឬមិនគួរធ្វើ។

**ឃ.ខ្លឹមសារត្រួតពិនិត្យ**

ការងារត្រួតពិនិត្យរបស់គណបក្ស ត្រូវផ្ដើមចេញពីភារកិច្ចនយោបាយ និងការងារដឹកនាំ កសាង និងពង្រឹងគណបក្ស។ ទន្ទឹមនឹងនោះ ការងារត្រួតពិនិត្យត្រូវកំណត់ គោលដៅ និងខ្លឹមសារសម្រាប់សកម្មភាពរបស់ខ្លួន គឺបម្រើឲ្យភារកិច្ចនយោបាយ ការងារដឹកនាំ កសាង និងពង្រឹងគណបក្សឲ្យទទួលបានជោគជ័យ។

ភ្ជាប់ជាប់ការងារត្រួតពិនិត្យជាប្រចាំ គឺជារូបភាពយ៉ាងសំខាន់ ពីព្រោះយើងអាចរកឃើញបានទាន់ពេលវេលានូវគុណសម្បត្តិរបស់មន្ត្រី សមាជិក ក៏ដូចជាអង្គការចាត់តាំងគណបក្ស ដើម្បីពង្រីកបន្ថែម និងបង្កើនសកម្មភាព និងរកឃើញនូវគុណវិបត្តិរបស់មន្ត្រីសមាជិក និងអង្គការចាត់តាំងគណបក្ស ដើម្បីកែលម្អ។

ត្រួតពិនិត្យវិសាមញ្ញ សំដៅដល់ការស្រាវជ្រាវ និងដោះស្រាយឲ្យទាន់ពេលវេលានូវសភាពការណ៍ ដែលកើតឡើងដោយចៃដន្យ។ ត្រួតពិនិត្យវិសាមញ្ញ គឺជាការស្រាវជ្រាវស៊ីជម្រៅទៅលើបញ្ហាមួយ ឬពិនិត្យសន្និដ្ឋានផ្នែកណាមួយនោះ ក្នុងបណ្ដាផ្នែកការងារត្រួតពិនិត្យ។ មុខសញ្ញាត្រួតពិនិត្យអាចមានមួយ ឬមានច្រើន ហើយក្របខ័ណ្ឌត្រួតពិនិត្យអាចចង្អៀត ឬទូលាយ។ ខ្លឹមសារត្រួតពិនិត្យ អាចមានមួយ ឬមានច្រើនបញ្ហា ហើយរយៈពេលត្រួតពិនិត្យតាមករណីនីមួយៗ ខ្លី ឬ វែង គឺអាស្រ័យទៅលើគោលបំណង និងសំណូមពរនៃការត្រួតពិនិត្យ។

រូបភាពត្រួតពិនិត្យទាំងអស់ គឺមានផលប្រយោជន៍ដោយឡែកពីគ្នា របៀបធ្វើក៏ដោយឡែកពីគ្នា ក៏ប៉ុន្តែមានទំនាក់ទំនងជាមួយគ្នា បំពេញឲ្យគ្នាទៅវិញទៅមក សុទ្ធតែមានគោលបំណងរក្សាវិន័យរបស់គណបក្ស បម្រើនូវភារកិច្ចនយោបាយ និងការងារកសាងគណបក្សឲ្យបានល្អ។ នៅកន្លែងណា ដែលគណៈកម្មាធិការគណបក្សយកចិត្តទុកដាក់ ដឹកនាំ ណែនាំហ្មត់ចត់ គឺនៅកន្លែងនោះ ការងារ

ត្រួតពិនិត្យរបស់គណបក្ស នឹងមានការរីកចម្រើន និងមានប្រសិទ្ធភាពល្អ។

ការងារត្រួតពិនិត្យអង្គការចាត់តាំង និងមន្ត្រី សមាជិកគណបក្សប្រព្រឹត្តល្មើសខុសឆ្គង មានខ្លឹមសារត្រួតពិនិត្យជាច្រើន ដូចជាប្រព្រឹត្តល្មើសលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងគណបក្ស គោលនយោបាយរបស់គណបក្ស ច្បាប់របស់រដ្ឋ លក្ខណៈសម្បត្តិ និងភារកិច្ចរបស់អង្គការចាត់តាំង មន្ត្រី សមាជិកគណបក្សជាដើម។

ត្រួតពិនិត្យមន្ត្រី សមាជិកគណបក្សដែលល្មើសវិន័យ គឺពិនិត្យវិនិច្ឆ័យរាល់បញ្ហាជាក់ស្តែងរបស់សមាជិក។ មន្ត្រីត្រួតពិនិត្យចាំបាច់ត្រូវស្វែងយល់ពីតួនាទី ភារកិច្ច សភាពការណ៍ និងសកម្មភាពរបស់អង្គការចាត់តាំងគណបក្សនៅកន្លែងដែលមន្ត្រី សមាជិក ល្មើសវិន័យកំពុងស្ថិតក្នុងជីវភាព និងស្វែងយល់ពីតួនាទី ភារកិច្ចរបស់មន្ត្រី សមាជិកនោះ នៅក្នុងអង្គការចាត់តាំងគណបក្សនោះ ដើម្បីងាយស្រួលក្នុងការងារត្រួតពិនិត្យ សន្និដ្ឋានការខុសឆ្គងរបស់មន្ត្រី សមាជិកគណបក្ស ដោយសត្យានុម័តច្បាស់លាស់ ជៀសវាងការលើកយកហេតុផលដោយអត្តនោម័តមិនជាក់ស្តែង។

**ត្រូវយកចិត្តទុកដាក់ត្រួតពិនិត្យ បណ្តាករណីមួយចំនួនដូចខាងក្រោម ៖**

**ឃ.១-ល្មើសលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងគណបក្ស ៖** លក្ខន្តិកៈគណបក្សជាធម្មនុញ្ញរបស់គណបក្សទាំងមូល ជាការសម្តែងឡើង

ដោយប្រមូលផ្តុំនូវវិន័យរបស់គណបក្ស ព្រមទាំងការកំណត់នូវគោលបំណង គោលការណ៍ជាសារវន្តអំពីការកសាងគណបក្ស រចនាសម្ព័ន្ធអង្គការចាត់តាំងរបស់គណបក្ស ភារកិច្ច និងសិទ្ធិអំណាចរបស់អង្គការចាត់តាំង គណបក្ស និងមន្ត្រី សមាជិកគណបក្ស ការដឹកនាំរបស់គណបក្សចំពោះស្ថាប័នរដ្ឋ និងអង្គការមហាជន ការដាក់វិន័យក្នុងគណបក្ស។

ការដឹកនាំគ្រប់វិស័យរបស់គណបក្ស ក៏ដូចជាការងារដឹកនាំ កសាង និងពង្រឹងគណបក្ស ត្រូវបានដំណើរការលើមូលដ្ឋានដូចបានកំណត់ក្នុងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង គណបក្ស។ ហេតុដូច្នេះ រាល់អង្គការចាត់តាំងគណបក្ស និងមន្ត្រី សមាជិកគណបក្សត្រូវប្រតិបត្តិតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយនិងសេចក្តីសម្រេចចិត្តនានារបស់គណបក្សដោយម៉ឺងម៉ាត់ ត្រូវតស៊ូពុះពារ និងទប់ស្កាត់ ឲ្យបានទាន់ពេលវេលានូវបាតុភាពបំពានល្មើសលក្ខន្តិកៈគណបក្ស។ ប្រការសំខាន់ដែលត្រូវយកចិត្តទុកដាក់បំផុតគឺ ការប្រតិបត្តិគោលការណ៍ប្រជាធិបតេយ្យទូលំទូលាយ អនុវត្តរបបសមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ ភាគតិច គោរពភាគច្រើន សមាជិកម្នាក់ៗត្រូវគោរពអង្គការចាត់តាំង ថ្នាក់ក្រោមគោរពថ្នាក់លើ គណបក្សទាំងមូលគោរពមហាសន្និបាតតំណាងទូទាំងប្រទេស និងគណៈកម្មាធិការកណ្តាលនៃ

គណបក្ស[2] ព្រមទាំងប្រតិបត្តិដោយឥតលក្ខខណ្ឌទៅតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និងសេចក្តីសម្រេចចិត្តនានារបស់គណបក្ស។ ក្នុងគណបក្សមិនត្រូវផ្តាច់ការ ឯកសិទ្ធិ និងមិនត្រូវមានបក្ខពួកនិយម។

**ឃ.២-លើ្មសលក្ខណៈសម្បត្តិ និងភារកិច្ចសមាជិកគណបក្ស**

( ជំពូកIII មាត្រាទី៥ មាត្រាទី៧ នៃលក្ខន្តិកៈគណបក្ស )។ លក្ខណៈសម្បត្តិរបស់សមាជិកគឺ ៖ (១)ពលរដ្ឋកម្ពុជាដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ (២)មានឧត្តមគតិស្នេហាជាតិមាតុភូមិ លទ្ធិប្រជាធិបតេយ្យ គាំទ្រកម្មវិធីនយោបាយ និងលក្ខន្តិកៈគណបក្ស (៣)មានគុណធម៌ និងទំនាក់ទំនងល្អជាមួយប្រជាជន ហើយត្រូវបានប្រជាជនស្រឡាញ់ រាប់អាន ជឿទុកចិត្ត (៤)មិនមែនជាសមាជិកគណបក្សនយោបាយដទៃ។ ចំណែកឯភារកិច្ចរបស់សមាជិកមានដូចជា ៖ (១)ខិតខំប្រតិបត្តិឲ្យបានត្រឹមត្រូវតាមកម្មវិធីនយោបាយ និងលក្ខន្តិកៈគណបក្ស (២)កសាងទំនាក់ទំនងល្អជាមួយប្រជាជន និងខិតខំឃោសនា ផ្សព្វផ្សាយអំពីកម្មវិធីនយោបាយរបស់គណបក្ស ច្បាប់របស់រដ្ឋ ដល់ប្រជាជន (៣)ត្រូវថែរក្សា ឆ្លុងសាមគ្គី ឯកភាពផ្ទៃក្នុង រក្សាការសម្ងាត់របស់គណបក្ស ជានិច្ចកាលជួយមតិគ្នាទៅវិញទៅមក ដើម្បីការរីកចម្រើន (៤)ខិតខំរៀនសូត្រលើកកម្ពស់សមត្ថភាព និងគុណធម៌ ដើម្បីសម្រេចភារកិច្ចជូនជាតិមាតុភូមិ។

[2]មាត្រាទី១០ លក្ខន្តិកៈគណបក្ស

***ឃ.៣-ល្មើសច្បាប់របស់រដ្ឋ*** *ក្នុងស្ថានភាពដែលគណបក្សកំពុងកាន់អំណាចដឹកនាំប្រទេស កម្មវិធីនយោបាយរបស់គណបក្សត្រូវបានប្រែក្លាយទៅជាកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។ បណ្តាអង្គការចាត់តាំងគណបក្ស និងមន្ត្រី សមាជិកគណបក្សដែលល្មើសច្បាប់របស់រដ្ឋ គឺត្រូវទទួលការត្រួតពិនិត្យពីអង្គការចាត់តាំងគណបក្សផង និងពីស្ថាប័នច្បាប់របស់រដ្ឋផង ដោយគ្មានអន្តរាគមន៍ ការពារនូវការខុសឆ្គងនោះឡើយ ត្រូវគោរពសិទ្ធិអំណាចរបស់ស្ថាប័នរដ្ឋ និងអនុវត្តម៉ឺងម៉ាត់តាមច្បាប់របស់រដ្ឋ* ***"ល្មើសច្បាប់របស់រដ្ឋ គឺល្មើសនឹងវិន័យរបស់គណបក្ស"។***

## ខ.នីតិវិធីដំណើរការពិនិត្យវិនិច្ឆ័យដាក់វិន័យ

*នៅពេលមានមន្ត្រី សមាជិក ឬអង្គការចាត់តាំងគណបក្សប្រព្រឹត្តល្មើសខុសឆ្គង ដល់កម្រិតត្រូវដាក់វិន័យ គណៈកម្មាធិការត្រួតពិនិត្យ ចាំបាច់ត្រូវតែអនុវត្តនូវកិច្ចការសំខាន់ ទាំងឡាយដូចតទៅ ៖*

***ង.១-****ក្តាប់សភាពការណ៍ខុសឆ្គង និងរៀបចំផែនការ គណៈកម្មាធិការគណបក្ស សាខាគណបក្ស ត្រូវរៀបចំផែនការដំណើរការពិនិត្យវិនិច្ឆ័យ ក្តាប់សភាពការណ៍ខុសឆ្គង និងប្រកាសឲ្យអ្នកប្រព្រឹត្តខុសឆ្គងដឹង ដើម្បីធ្វើការស្វ័យត្រួតពិនិត្យ និងរាយការណ៍ចំពោះមុខសាខាគណបក្ស កំណត់ថ្ងៃត្រួតពិនិត្យក្នុងសាខាគណបក្ស។*

***ង.២-****បង្គាប់ឲ្យមន្ត្រី សមាជិកគណបក្សដែលខុសឆ្គងត្រូវធ្វើការស្វ័យត្រួតពិនិត្យចំពោះមុខសាខាគណបក្ស ឬគណៈកម្មាធិការ*

ត្រួតពិនិត្យ សន្និដ្ឋាន និងវិនិច្ឆ័យដាក់វិន័យ ៖ ណែនាំ និងលើកទឹកចិត្តឲ្យមន្ត្រី សមាជិកគណបក្ស ដែលល្មើសខុសឆ្គងសរសេររបាយការណ៍ត្រួតពិនិត្យផ្ទាល់ខ្លួន។ ក្នុងករណីពិនិត្យវិនិច្ឆ័យមន្ត្រី សមាជិកគណបក្ស ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់លើគណៈកម្មាធិការត្រួតពិនិត្យថ្នាក់លើ ចាំបាច់ត្រូវផ្ញៀតយកការវាយតម្លៃឯកភាពរបស់គណៈកម្មាធិការគណបក្សមូលដ្ឋាន អំពីសភាពការណ៍ខុសឆ្គង និងផ្ញៀតយកមតិណែនាំ របស់គណៈកម្មាធិការគណបក្សថ្នាក់លើរបស់ខ្លួនមុនពេលសន្និដ្ឋាន ពិនិត្យវិនិច្ឆ័យដាក់វិន័យ។ ពេលប្រជុំត្រួតពិនិត្យមន្ត្រី សមាជិកគណបក្សដែលខុសឆ្គងត្រូវអានរបាយការណ៍ស្វ័យត្រួតពិនិត្យ ហើយសាមីខ្លួនមានស្មារតីភ្ញាក់រលឹកទទួលយកនូវរូបភាពវិន័យមួយ។ នៅពេលពិនិត្យសន្និដ្ឋានការខុសឆ្គង គឺត្រូវតែយកចិត្តទុកដាក់វិភាគមូលហេតុខុសឆ្គង និងការទទួលខុសត្រូវរបស់អង្គការចាត់តាំងគណបក្ស។ ប្រសិនបើកម្រិតវិន័យស្តីបន្ទោស សេចក្តីសម្រេចគឺមានប្រសិទ្ធភាពភ្លាមហើយសាខាគណបក្សធ្វើទម្រង់បែបបទសំណុំរឿងរាយការណ៍ ជូនគណៈកម្មាធិការគណបក្សថ្នាក់លើបានជ្រាបដោយផ្ទាល់ដើម្បីតាមដាន។ ចំពោះការដាក់វិន័យដកតួនាទីពីសមាជិកគណៈកម្មាធិការសាខាគណបក្ស ឬបញ្ចេញពីគណបក្ស សាខាគណបក្សត្រូវរៀបចំសំណុំរឿងស្នើឡើង គណៈកម្មាធិការគណបក្ស ដែលគ្រប់គ្រងមន្ត្រី សមាជិកគណបក្សនោះ ពិនិត្យសម្រេច។

**៨.៣**-ពិនិត្យវិនិច្ឆ័យដាក់វិន័យ ពេលទទួលបានរបាយការណ៍ស្នើដាក់វិន័យគណៈកម្មាធិការត្រួតពិនិត្យ របស់គណៈកម្មាធិការគណបក្សទៅជួបមន្ត្រី សមាជិក ឬអង្គការចាត់តាំងគណបក្សល្មើសវិន័យ និងបើកកិច្ចប្រជុំសម្រេចដាក់វិន័យ។

**៨.៤**-ប្រកាសសេចក្តីសម្រេច និងរៀបចំសំណុំលិខិតសម្រាប់រក្សាទុក។

**៨.៥**-អង្គការចាត់តាំងគណបក្ស ដែលចេញសេចក្តីសម្រេចដាក់វិន័យ និងសាខាគណបក្សដែលមានមន្ត្រី សមាជិកគណបក្សរងវិន័យ មានសមត្ថកិច្ចតាមដាន អប់រំ មន្ត្រី សមាជិកគណបក្សនោះ។

## III-នីតិវិធីនៃការត្រួតពិនិត្យរកមុខសញ្ញាខុសឆ្គង

គណៈកម្មាធិការត្រួតពិនិត្យ ចាំបាច់ត្រូវត្រួតពិនិត្យតាមដានជាប្រចាំ នូវការអនុវត្តភារកិច្ចនយោបាយរបស់អង្គការចាត់តាំងគណបក្ស មន្ត្រី សមាជិកគណបក្សរកឲ្យឃើញទាន់ពេលវេលានូវអង្គការចាត់តាំងគណបក្ស មន្ត្រី សមាជិកគណបក្សដែលមានតម្រុយខុសឆ្គង អសកម្ម ដើម្បីទប់ស្កាត់បាតុភាពខុសឆ្គងធ្ងន់ធ្ងរ និងអប់រំសមាជិកគណបក្សដទៃទៀត កុំឲ្យអនុវត្តខុសឆ្គង។ ប៉ុន្តែបើអង្គការចាត់តាំង មន្ត្រី សមាជិកគណបក្សមានការខុសឆ្គងធ្ងន់ធ្ងរដល់កម្រិតដាក់វិន័យនោះ គឺចាំបាច់ត្រូវតែធ្វើការត្រួតពិនិត្យឲ្យបានត្រឹមត្រូវតាមគោលការណ៍របស់គណបក្ស។

មានវិធីសាស្ត្រជាច្រើន ដែលអាចប្រើប្រាស់ជាមធ្យោបាយក្នុងការត្រួតពិនិត្យ គួបផ្សំនឹងស្មារតីច្ចាតវាងវៃរបស់មន្ត្រីធ្វើការងារត្រួតពិនិត្យ។ វិធីមួយដែលមានប្រសិទ្ធភាពក្នុងបណ្តាវិធីទាំងឡាយ គឺការគួបផ្សំយ៉ាងជិតស្និទ្ធរវាងការងារត្រួតពិនិត្យ ការអនុវត្តគោលការណ៍ គោលនយោបាយ សេចក្តីសម្រេចចិត្តនានារបស់គណបក្សជាមួយនឹងការងារត្រួត ពិនិត្យ អង្គការចាត់តាំង មន្ត្រី សមាជិកគណបក្សប្រព្រឹត្តល្មើសខុសឆ្គង។ ឆ្លងតាមសកម្មភាពនេះ យើងអាចវាយតម្លៃបានត្រឹមត្រូវនូវគុណសម្បត្តិ និងការខ្វះខាតរបស់អង្គការចាត់តាំង មន្ត្រី សមាជិកគណបក្ស។

ប្រភពព័ត៌មានផ្សេងៗទៀត ដែលអាចប្រើប្រាស់បាន គឺរបាយការណ៍នានា ប្រព័ន្ធសារព័ត៌មាន បណ្តាញសង្គម បណ្តឹង (រាប់ទាំងបណ្តឹងមានឈ្មោះ ឬអនាមិក)។ល។

## ១.វិធីដំណើរការស្រាវជ្រាវ

បើអង្គការចាត់តាំង ឬមន្ត្រី សមាជិកគណបក្សដែលមានតួនាទី ត្រូវសុំគោលការណ៍ពីគណៈកម្មាធិការគណបក្សដែលគ្រប់គ្រងផ្ទាល់ ដើម្បីផ្អាកការងារបណ្តោះអាសន្នសម្រាប់ធ្វើការត្រួតពិនិត្យ ៖

ក-ស្រាវជ្រាវឯកសារ ភស្តុតាងដែលពាក់ព័ន្ធ។

ខ-ពិនិត្យពិចារណាលើឯកសារ រកឲ្យឃើញអ្វីដែលច្បាស់ និងអ្វីដែលមិនទាន់ច្បាស់លាស់។

គ-ជួបជាមួយអង្គការចាត់តាំង ដែលមន្ត្រី សមាជិកគណបក្សនោះកំពុងជីវភាព ឬអង្គការចាត់តាំងគណបក្សដែលគ្រប់គ្រងមន្ត្រី សមាជិកគណបក្សនោះ។

ឃ-ជួបជាមួយមន្ត្រី សមាជិកគណបក្ស មហាជន ប្រជាជន ដែលនៅជុំវិញ និង អ្នកដឹងឮអំពីករណីដែលបានកើតឡើង ។

ង-ជួបជាមួយសាមីខ្លួន ដើម្បីឲ្យគេបញ្ជាក់ការពិត។

ច-ក្រុមការងារស្រាវជ្រាវ ត្រូវធ្វើរបាយការណ៍ពីលទ្ធផលស្រាវជ្រាវ ជូនគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការគណបក្ស ដើម្បីពិនិត្យពិចារណា និងវិនិច្ឆ័យដាក់វិន័យ។

ឆ-ចូរតាមការងារស្រាវជ្រាវរកមុខសញ្ញាខុសឆ្គង បើពិនិត្យឃើញថា មន្ត្រី សមាជិកក្នុងអង្គការចាត់តាំងគណបក្សនោះមានការប្រព្រឹត្តខុសឆ្គងច្រើននាក់ គឺអង្គការចាត់តាំងគណបក្សនោះត្រូវតែទទួលការដាក់វិន័យ។

<u>**កំណត់សម្គាល់**</u> ៖ រាល់ការជួបធ្វើការ ត្រូវធ្វើកំណត់ហេតុ។

## ២. ការប្រកាសសេចក្តីសម្រេចដាក់វិន័យ

ក្រោយពីបានទទួលសេចក្តីសម្រេចដាក់វិន័យ របស់អង្គការចាត់តាំងគណបក្ស ដែលមានសមត្ថកិច្ចដាក់វិន័យ គណៈកម្មាធិការគណបក្សត្រូវប្រកាសសេចក្តីសម្រេចនោះ នៅចំពោះមុខសាខាគណបក្ស (ចំពោះសមាជិកធម្មតា) ដើម្បីឲ្យសមាជិកគណបក្ស

ដែលទទួលវិន័យបានជ្រាប ប្រតិបត្តិតាម និងដើម្បីអប់រំមន្ត្រី សមាជិកដទៃទៀតរបស់គណបក្ស។

ចំពោះអង្គការចាត់តាំង មន្ត្រី សមាជិកគណបក្ស ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់លើ ត្រូវមានតំណាងគណៈកម្មាធិការត្រួតពិនិត្យថ្នាក់នោះ ជាអ្នកប្រកាសដោយផ្ទាល់ ហើយត្រូវមានតំណាងគណៈកម្មាធិការគណបក្សមូលដ្ឋាន និងគ្រប់សាខាគណបក្សចំណុះទាំងអស់ចូលរួម ។

**IV-សមត្ថកិច្ចដាក់វិន័យ** (លក្ខន្តិកៈគណបក្សជំពូកIX មាត្រាទី២៦ និងគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ស្តីពីតួនាទី សិទ្ធិរបស់គណៈកម្មាធិការគណបក្សគ្រប់ថ្នាក់)

**១.ចំពោះអង្គការចាត់តាំង**

- ការដាក់វិន័យដោយរូបភាពស្តីបន្ទោស ចំពោះអង្គការចាត់តាំងគណបក្ស ត្រូវបានគណៈកម្មាធិការនៃគណបក្សថ្នាក់លើផ្ទាល់សម្រេច។

- ការដាក់វិន័យដោយរូបភាពរំសាយ ចំពោះអង្គការចាត់តាំងគណបក្ស ត្រូវបានគណៈកម្មាធិការនៃគណបក្សថ្នាក់លើផ្ទាល់ឯកភាព ហើយស្នើឡើងគណៈកម្មាធិការគណបក្សថ្នាក់លើមួយទៀតសម្រេច និងរាយការណ៍ជូនគណៈកម្មាធិការកណ្តាលនៃគណបក្ស។

## ២.ចំពោះសមាជិក

- សាខាគណបក្ស មានសិទ្ធិសម្រេចដាក់វិន័យស្តីបន្ទោស ចំពោះសមាជិកជម្មតាណា ដែលប្រព្រឹត្តល្មើសខុសឆ្គងក្នុងក្របខ័ណ្ឌ សាខាគណបក្ស។

- គណៈកម្មាធិការនៃគណបក្សថ្នាក់លើផ្ទាល់របស់សាខា គណបក្ស មានសិទ្ធិសម្រេចដាក់វិន័យ ស្តីបន្ទោស ចំពោះប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសាខាគណបក្ស។

- គណៈកម្មាធិការនៃគណបក្សថ្នាក់ណា ដែលមានសិទ្ធិ ចេញសេចក្តីសម្រេចតែងតាំង ឬយល់ព្រមទទួលស្គាល់ គឺគណៈ កម្មាធិការគណបក្សថ្នាក់នោះ មានសិទ្ធិសម្រេចដាក់វិន័យ ស្តីបន្ទោស ឬដកតួនាទី ពីសមាជិកគណៈកម្មាធិការនៃគណបក្ស និងពីប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសាខាគណបក្ស។

- ការដាក់វិន័យ ដោយរូបភាពបញ្ចេញពីសមាជិកគណៈ កម្មាធិការកណ្តាល អាស្រ័យដោយសន្និបាតពេញអង្គនៃគណៈកម្មា ធិការកណ្តាល តាមសំណើរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការ កណ្តាល ហើយរាយការណ៍ជូនមហាសន្និបាតតំណាងទូទាំងប្រទេស របស់គណបក្ស។ ក្នុងករណីដែលសមាជិកគណៈកម្មាធិការកណ្តាល បានប្រព្រឹត្តកំហុសឆ្គងធ្ងន់ធ្ងរ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី បទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរទោស គណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្តាល មានសិទ្ធិសម្រេចបញ្ចេញពីសមាជិក

គណៈកម្មាធិការកណ្តាល ហើយរាយការណ៍ជូនគណៈកម្មាធិការកណ្តាល និងមហាសន្និបាតតំណាងទូទាំងប្រទេសរបស់គណបក្ស។

-គណៈកម្មាធិការនៃគណបក្សថ្នាក់លើណា ដែលមានសិទ្ធិសម្រេចបញ្ចូលជាសមាជិក គឺគណៈកម្មាធិការគណបក្សថ្នាក់នោះ មានសិទ្ធិសម្រេចដាក់វិន័យបញ្ចេញពីសមាជិក ចំពោះតែសមាជិកធម្មតា។ ចំពោះមន្ត្រី សមាជិកគណបក្សណាដែលមានតួនាទីតាមលំដាប់ថ្នាក់ អាស្រ័យដោយគណៈកម្មាធិការនៃគណបក្សថ្នាក់លើគ្រប់គ្រងមន្ត្រី សមាជិកគណបក្សនោះ ចេញសេចក្តីសម្រេចបញ្ចេញពីសមាជិក។ ក្នុងករណីបញ្ចេញពីសមាជិក គឺត្រូវមានការឯកភាពតិចបំផុត ២ភាគ៣ នៃសមាជិកគណៈកម្មាធិការគណបក្ស។

យោងតាមស្មារតីនៃមាត្រា និងគោលការណ៍ណែនាំខាងលើនេះ យើងសង្កេតឃើញថា ការដាក់វិន័យត្រឹមការស្តីបន្ទោសដែលជាការដាក់វិន័យកម្រិតស្រាល គឺការសម្រេចត្រឹមតែសាខា ឬគណៈកម្មាធិការគណបក្សថ្នាក់លើសាខា ឬគណៈកម្មាធិការគណបក្សថ្នាក់ណាដែលមានសិទ្ធិចេញសេចក្តីសម្រេចតែងតាំង ឬយល់ព្រមទទួលស្គាល់ប៉ុណ្ណោះ។ ប្រសិនបើការដាក់វិន័យឈានទៅដល់កម្រិតដកតួនាទី ដែលជាការដាក់វិន័យធ្ងន់ធ្ងរកម្រិតបន្ថែរនោះ គឺការសម្រេច ត្រូវធ្វើឡើងដោយគណៈកម្មាធិការនៃគណបក្សថ្នាក់ណាដែលមានសិទ្ធិចេញសេចក្តីសម្រេចតែងតាំង ឬ យល់ព្រមទទួលស្គាល់។ ចំណែកការបញ្ចេញពីសមាជិកគណបក្ស ជាការដាក់វិន័យ

ធ្ងន់ធ្ងរបំផុតនោះ គឺត្រូវបែកចេញជា៣ គឺ ករណីសមាជិកគណបក្សធម្មតា សមាជិកគណបក្សដែលមានតួនាទីតាមលំដាប់ និងសមាជិកគណៈកម្មាធិការកណ្តាល។ សមាជិកធម្មតាដែលប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ហើយឈានដល់ការសម្រេចបញ្ចេញពីគណបក្ស គឺគណៈកម្មាធិការនៃគណបក្សថ្នាក់លើណា ដែលមានសិទ្ធិសម្រេចយល់ព្រមបញ្ចូលជាសមាជិក គឺគណៈកម្មាធិការគណបក្សថ្នាក់នោះមានសិទ្ធិសម្រេចដាក់វិន័យបញ្ចេញពីសមាជិក។ ចំពោះសមាជិកគណបក្សណាដែលមានតួនាទីតាមលំដាប់ថ្នាក់ អាស្រ័យដោយគណៈកម្មាធិការនៃគណបក្សថ្នាក់លើគ្រប់គ្រងសមាជិកគណបក្សនោះ ជាអ្នកចេញសេចក្តីសម្រេចបញ្ចេញពីសមាជិក។ ក្នុងករណីបញ្ចេញពីសមាជិក គឺត្រូវមានការឯកភាពតិចបំផុត ២ភាគ៣ នៃសមាជិកគណៈកម្មាធិការគណបក្ស ពីព្រោះជារូបភាពវិន័យខ្ពស់បំផុតដែលកំណត់ពីអាយុជីវិតខាងនយោបាយរបស់សមាជិក ក្នុងករណីមានមតិភាគច្រើនយល់ព្រម តែពុំទាន់គ្រប់ចំនួន ២ភាគ៣នោះ គឺត្រូវរាយការណ៍ទៅតាមដាក់ស្តែង។

**<u>កំណត់សម្គាល់</u> ៖ *អង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ដែលមានសមត្ថកិច្ចដាក់វិន័យ ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍យុត្តិធម៌ ច្បាស់លាស់ ពិតប្រាកដ និងទាន់ពេលវេលា។***

និយាយជារួម ការងារត្រួតពិនិត្យរបស់គណបក្ស ជាការងារដ៏សំខាន់ចាំបាច់មិនអាចខ្វះបានក្នុងការងារដឹកនាំ កសាង និងពង្រឹង

គណបក្ស ហើយក៏ជាការងាររបស់អង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ សមាជិកគណបក្សគ្រប់រូប និងគណបក្សទាំងមូល។

ការងារត្រួតពិនិត្យមានអត្ថន័យ និងមានឥទ្ធិពលយ៉ាងជ្រាលជ្រៅក្នុងការជំរុញ និងរួមចំណែកធានាឲ្យលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និងសេចក្តីសម្រេចចិត្តនានារបស់គណបក្សបានជ្រួតជ្រាប និងអនុវត្តបានត្រឹមត្រូវ ដើម្បីរួមចំណែកក្នុងការងារកសាងគណបក្សឲ្យរឹងមាំព្រមទាំងកសាង ការពារជួរមន្ត្រី សមាជិកគណបក្ស ឲ្យបានល្អស្អាតស្អំ។

ដើម្បីសម្រេចបាននូវតួនាទី និងភារកិច្ចដែលគណបក្សប្រគល់ឲ្យ គណៈកម្មាធិការត្រួតពិនិត្យគ្រប់លំដាប់ថ្នាក់ ត្រូវយកចិត្តទុកដាក់ពង្រឹងអង្គការចាត់តាំងគណបក្សបណ្តុះបណ្តាល និងបំពាក់បំប៉នសមត្ថភាពមន្ត្រី ដើម្បីឲ្យការបំពេញការងារទទួលបានលទ្ធផល និងមានប្រសិទ្ធភាព។

មន្ត្រីដែលបំពេញការងារត្រួតពិនិត្យ ត្រូវជាអ្នកមានទស្សនៈ គោលជំហររឹងមាំ មានសមត្ថភាព គុណធម៌ សីលធម៌ល្អ យុត្តិធម៌ ស្មោះត្រង់ មិនលំអៀង។ ត្រូវមានការយល់ដឹងអំពីការងារកសាងគណបក្ស ក្តាប់ជាប់លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និងសេចក្តីសម្រេចចិត្តនានារបស់គណបក្ស និងត្រូវមានការយល់ដឹងជាមូលដ្ឋាន អំពី

ភាពចាំបាច់នៃការងារត្រួតពិនិត្យគណបក្ស ព្រមទាំងត្រូវក្តាប់សភាពការណ៍ជាក់ស្តែងឲ្យបានច្បាស់លាស់ ពិតប្រាកដ និងទាន់ពេលវេលា។

**V-ការរក្សាទុកសំណុំលិខិត**

គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ មានភារៈស្រាវជ្រាវឯកសារសំណុំលិខិត និងរក្សាសំណុំលិខិតដាក់វិន័យរបស់មន្ត្រី សមាជិក និងអង្គការចាត់តាំងគណបក្ស។ សំណុំលិខិតរក្សាទុករួមមាន ៖

-ប្រវត្តិរូបសង្ខេប និងរបាយការណ៍ត្រួតពិនិត្យផ្ទាល់ខ្លួន

-បណ្តាកំណត់ហេតុរបស់អង្គប្រជុំសាខាគណបក្ស គណៈកម្មាធិការគណបក្សថ្នាក់លើ ដែលមានសមត្ថកិច្ច ក្នុងការពិនិត្យវិនិច្ឆ័យដាក់វិន័យ

-របាយការណ៍ស្នើដាក់វិន័យ របស់គណៈកម្មាធិការគណបក្សថ្នាក់ក្រោម និងរបស់គណៈកម្មាធិការត្រួតពិនិត្យ

-បណ្តារបាយការណ៍បញ្ជាក់បន្ថែម និងឯកសារភស្តុតាងចាំបាច់ ពាក់ព័ន្ធដល់រឿងដាក់វិន័យ

-សេចក្តីសម្រេចដាក់វិន័យ៕

# ឯកសារ

# ស្ដីពីការទទួល និងដោះស្រាយបណ្ដឹង

## I-សេចក្ដីផ្ដើម

*ការទទួល និងដោះស្រាយបណ្ដឹង គឺជាភារកិច្ចមួយក្នុងចំណោមភារកិច្ចទាំង៩ របស់គណៈកម្មាធិការត្រួតពិនិត្យគណបក្សគ្រប់ថ្នាក់ ដែលបានចែងក្នុងសេចក្ដីសម្រេចលេខ ១០២៥/១៥ សស.គក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ និងលេខ ១២៥៤/១៥ សស.គក ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ របស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ក្នុងចំណុច*"**ខ**"*ស្ដីអំពី***ភារកិច្ច***ត្រង់ចំណុច៣* "***ទទួល និងដោះស្រាយបណ្ដឹងបរិហារ និងបណ្ដឹងតវ៉ា ចំពោះអង្គការចាត់តាំង ឬមន្ត្រីសមាជិកគណបក្ស ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគណបក្សថ្នាក់ខ្លួន***"។ *បណ្ដឹង គឺជាការរួមយោបល់របស់ប្រជាជន មហាជន និងសមាជិកគណបក្ស និងជាការអនុវត្តសិទ្ធិប្រជាធិបតេយ្យក្នុងគណបក្សរបស់សមាជិកគណបក្ស មាត្រាទី៨ នៃលក្ខន្តិកៈរបស់គណបក្ស* "**សិទ្ធិរបស់សមាជិក**" *ចំណុច៣* "***ជួយយោបល់ និងលើកមតិតវ៉ារបស់ខ្លួនទៅគណៈកម្មាធិការគណបក្សគ្រប់ថ្នាក់***" ។

បណ្ដឹងមានជាច្រើនប្រភេទ ហើយខ្លឹមសារបណ្ដឹងក៏មានលក្ខណៈខុសគ្នាដែរ ដូចជា បណ្ដឹងបរិហារ បណ្ដឹងតវ៉ា និងបណ្ដឹងទាមទារ តែនៅក្នុងការងារគណបក្ស ការទទួល និងដោះស្រាយបណ្ដឹង បែកចេញតែជា ២ ប្រភេទប៉ុណ្ណោះ គឺ ៖ ការទទួល និងដោះស្រាយបណ្ដឹងបរិហារ និងបណ្ដឹងតវ៉ាអំពីការដាក់វិន័យរបស់គណបក្ស ។

ដើម្បីអនុវត្តភារកិច្ចដូចបានលើកឡើងខាងលើ ទាមទារគណៈកម្មាធិការត្រួតពិនិត្យគណបក្សគ្រប់ថ្នាក់ ត្រូវយកចិត្តទុកដាក់ធ្វើដោយហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយ ។

ការដោះស្រាយបណ្ដឹង គឺជាការចូលរួមក្នុងការអនុវត្តអភិក្រមទាំង៥ ដែល**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្ស បានដាក់ចេញនៅក្នុងសន្និបាតគណៈកម្មាធិការកណ្ដាលលើកទី៤១ អាណត្តិទីV កាលពីថ្ងៃទី១៨-១៩-២០ ខែធ្នូ ឆ្នាំ២០១៨ "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" និងបាវចនា ២ គឺ "**ធ្វើកំណែទម្រង់ខាងក្នុង និងបង្កើនមិត្តខាងក្រៅដោយស្មារតីឯកភាពជ្រៅ**"។

## II-បណ្ដឹងបរិហារ

### ១.អត្ថន័យ

**បណ្ដឹងបរិហារ** គឺជាប្រភេទជូនដំណឹងដ៏សំខាន់ព្រោះតាមរយៈបណ្ដឹងបរិហារធ្វើឲ្យអង្គការ ចាត់តាំងគណបក្សដែលមាន

សមត្ថកិច្ចអាចយល់ដឹងអំពីសំណូមពរបំណង ប្រាថ្នារបស់មហាជន និងមន្ត្រី សមាជិកគណបក្ស ព្រមទាំងស្វែងយល់បន្ថែមទៀតអំពីសភាពការណ៍ សកម្មភាពរបស់ស្ថាប័ន អង្គការចាត់តាំងគណបក្ស របស់មន្ត្រី សមាជិកគណបក្សដែលត្រូវគេប្ដឹងបរិហារ អាចឃើញច្បាស់នូវការខ្វះខាត ភាពអសកម្ម ដែលត្រូវជម្នះកែលម្អឲ្យបានទាន់ពេលវេលា ។

**បណ្ដឹងបរិហារ** គឺជាការសម្ដែងមតិរបស់មហាជន ប្រជាជន មន្ត្រី សមាជិកគណបក្សឬអង្គការចាត់តាំងគណបក្ស ដើម្បីរួមចំណែកកសាង កែលម្អមន្ត្រី សមាជិកគណបក្ស ឬអង្គការចាត់តាំងគណបក្សដែលមានការខុសឆ្គងឲ្យមានការប្រែប្រួលល្អឡើងវិញ ប៉ុន្តែមានបណ្ដឹងបរិហារមួយចំនួនមានខ្លឹមសារមួលបង្កាច់ និយាយបំផ្លើសពីមន្ត្រីគណបក្ស ឬអង្គការចាត់តាំងគណបក្សក៏មានដែរ។

ការប្ដឹងបរិហារ គឺបណ្ដាលមកពីការមិនពេញចិត្តចំពោះទង្វើ សកម្មភាព អាកប្បកិរិយារបស់មន្ត្រីសមាជិកគណបក្ស ដែលមានការខុសឆ្គង មិនយកចិត្តទុកដាក់ស្ដាប់ គោរពយោបល់របស់មហាជន អាកប្បកិរិយាគំរាមកំហែង គាបសង្កត់អ្នកដែលហ៊ានបញ្ចេញមតិចំពោះការខុសឆ្គង ដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួននិងបក្ខពួក។ អ្នកប្ដឹងបរិហារ ប្រើប្រាស់វិធីជាច្រើនដើម្បីស្វែងរកការខុសឆ្គងរបស់មន្ត្រីគណបក្សនោះហើយ រាយការណ៍ជូនអង្គការចាត់តាំងគណបក្សដែលមានសមត្ថកិច្ចដូចជា រាយការណ៍ផ្ទាល់មាត់

បង្ហោះតាមបណ្ដាញសង្គម ឬធ្វើពាក្យប្ដឹងដោយចុះហត្ថលេខា ឬគ្មានចុះហត្ថលេខា។ បណ្ដឹងបរិហារ មានចេញមកពីច្រើនប្រភព ប៉ុន្ដែសរុបមកមាន ២ ប្រភេទ ៖

១. បណ្ដឹងមានដាក់ឈ្មោះអ្នកប្ដឹង

២. បណ្ដឹងអនាមិកមិនមានដាក់ឈ្មោះអ្នកប្ដឹង ។

**២.ខ្លឹមសារ**

ខ្លឹមសារបណ្ដឹងបរិហារ តែងតែពាក់ព័ន្ធដល់ច្រើនបញ្ហាខុសៗគ្នា លើគ្រប់វិស័យសកម្មភាពរបស់អង្គការចាត់តាំងគណបក្ស និងមន្ត្រី សមាជិកគណបក្សមានដូចជា៖

- បញ្ហាខាងនយោបាយ សេដ្ឋកិច្ច សមត្ថកិច្ច សិទ្ធិអំណាច លក្ខការណ៍ជីវភាពរស់នៅជាដើម មានបញ្ហាខ្លះពាក់ព័ន្ធដល់មនុស្សជាច្រើនរូប មានរឿងខ្លះបានកន្លងហួសយូរមកហើយ និងមានរឿងខ្លះទៀតកំពុងធ្វើឲ្យជះឥទ្ធិពល និងប៉ះពាល់ផលប្រយោជន៍ដល់គណបក្ស ព្រមទាំងប្រជាពលរដ្ឋ ។

ខ្លឹមសារបណ្ដឹងបរិហារមានភាពទូលំទូលាយណាស់ គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ត្រូវផ្អែកតាមសំណូមពរភារកិច្ច រកវិធីដោះស្រាយឲ្យបានសមស្រប និងទាន់ពេលវេលា តែមុនបង្អស់ត្រូវយកចិត្តទុកដាក់ដោះស្រាយបណ្ដឹងបរិហារ ដែលមានខ្លឹមសារសំខាន់ៗស្ថិតនៅក្នុងមូលដ្ឋានរបស់ខ្លួន និងបណ្ដាបញ្ហាដែលជះឥទ្ធិពលផ្ទាល់ដល់ការអនុវត្តការកិច្ចនយោបាយ កម្មវិធីនយោបាយ

គោលការណ៍ គោលនយោបាយ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និង សេចក្ដីសម្រេចចិត្តនានា របស់គណបក្ស ។

**ក.បណ្ដឹងបរិហារត្រូវយកចិត្តទុកដាក់ដោះស្រាយ**

ពាល់បណ្ដឹងបរិហារចំពោះមន្ត្រីសមាជិកគណបក្ស អង្គការចាត់តាំងគណបក្ស ដែលមានការពាក់ព័ន្ធ ៖ ការប្រតិបត្តិ គោលនយោបាយ សេចក្ដីសម្រេចចិត្ត សេចក្ដីណែនាំរបស់គណបក្ស ការធ្វើការងារដោយខ្វះស្មារតីទទួលខុសត្រូវ ការបង្កឲ្យមានការបែកបាក់សាមគ្គីផ្ទៃក្នុង ការបង្កឧបសគ្គដល់ការអនុវត្តការកិច្ចនយោបាយ ការងារកសាងគណបក្ស បាតុភាពអសកម្មរបស់អង្គការចាត់តាំងគណបក្ស មន្ត្រី សមាជិកគណបក្សដែលស្លឹកស្រពន់ សន្តិភាពស្កប់ស្កល់និយម រំលោភគោលការណ៍គណបក្សដែលធ្វើឲ្យមហាជនបាត់បង់ ជំនឿលើគណបក្ស ឬភាពមិនប្រក្រតីនានាក្នុងការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សលើគ្រប់វិស័យ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់គណបក្ស ។

ពាល់បណ្ដឹងបរិហារដែលមានខ្លឹមសារផ្សេងពីចំណុចទាំងឡាយខាងលើ ត្រូវផ្ទេរទៅឲ្យស្ថាប័នដែលមានការពាក់ព័ន្ធដោះស្រាយ ហើយត្រូវជូនដំណឹងភ្លាមឲ្យម្ចាស់បណ្ដឹងជ្រាប ទន្ទឹមនឹងនោះត្រូវតាមដានអំពីលទ្ធផលដោះស្រាយ ។

## ខ.បណ្តឹងបរិហារដែលពុំគួរដោះស្រាយ

-បណ្តឹងបរិហារដែលគណៈកម្មាធិការកណ្តាល បានដោះស្រាយ និងសម្រេចរួចហើយក្នុងករណីនេះ គណៈកម្មាធិការត្រួតពិនិត្យគ្រាន់តែពន្យល់ឲ្យអ្នកប្តឹង បានជ្រាបអំពីលទ្ធផលដោះស្រាយតែប៉ុណ្ណោះ ។

-បណ្តឹងបរិហារដែលលើកឡើងជារួមៗ គ្មានមូលដ្ឋានច្បាស់លាស់ ក្នុងករណីនេះគណៈកម្មាធិការត្រួតពិនិត្យត្រូវរក្សាទុកសិន ដើម្បីប្រើប្រាស់នៅពេលក្រោយដែលចាំបាច់។

- បណ្តឹងបរិហារដែលលើកអំពីហេតុការណ៍កើតឡើងជាយូរយារមកហើយហើយពុំបានជះឥទ្ធិពលគ្រោះថ្នាក់នាពេលបច្ចុប្បន្ននេះ ឬក៏គ្មានមូលដ្ឋានអ្វីដើម្បីសើរើមកបញ្ជាក់។

- បណ្តឹងបរិហារដែលមានខ្លឹមសារពាក់ព័ន្ធក្នុងរឿងគ្រួសារ។

- ករណីមុខសញ្ញាដែលគេប្តឹង កំពុងមានជំងឺជាទម្ងន់ហើយដែលមិនអាចស្តារសុខភាពឡើងវិញបាន។

- ប្រភេទបណ្តឹងបរិហារ ដែលមានលក្ខណៈមួលបង្កាច់ប្រឌិត បំផ្លើសការពិតអំពីអង្គការចាត់តាំង មន្ត្រី សមាជិកគណបក្ស ករណីនេះគណៈកម្មាធិការត្រួតពិនិត្យត្រូវបកស្រាយជូនអ្នកប្តឹងវិញ ដើម្បីការពារនូវសច្ចធម៌ យុត្តិធម៌ ភាពស្អាតស្អំ នៃអង្គការចាត់តាំងគណបក្ស និងសមាជិកគណបក្ស។

## ៣.សមត្ថកិច្ចដោះស្រាយ

*គណៈកម្មាធិការត្រួតពិនិត្យគណបក្សគ្រប់ថ្នាក់ រួមសហការជាមួយបណ្ដាថ្នាក់ បណ្ដាផ្នែកដែលមានការពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ចាត់តាំងការត្រួតពិនិត្យដោះស្រាយឲ្យបានទាន់ពេលវេលា និងហ្មត់ចត់ចំពោះករណីមន្ត្រី សមាជិកគណបក្សត្រូវគេប្ដឹងបរិហារ ដែលជាមន្ត្រីក្រោមការគ្រប់គ្រង របស់គណៈកម្មាធិការគណបក្សថ្នាក់ខ្លួន ទោះបីជាពាក្យបណ្ដឹងទាំងនោះមានដាក់ឈ្មោះអ្នកប្ដឹង ឬមិនមានដាក់ឈ្មោះអ្នកប្ដឹង ឬគេមកប្ដឹងផ្ទាល់ក៏ដោយ។*

### ក- បញ្ហាដែលត្រូវចៀសវាង

*- មិនត្រូវឲ្យបែកការសម្ងាត់នូវឈ្មោះអ្នកប្ដឹង និងសាក្សីជាដាច់ខាត*

*- មិនត្រូវឲ្យមុខសញ្ញាដែលត្រូវគេប្ដឹង ធ្វើជាអធិបតីក្នុងការដោះស្រាយ*

*- មិនត្រូវឲ្យមានសមាសភាពមន្ត្រីគណៈកម្មាធិការត្រួតពិនិត្យគណបក្ស ដែលមានទំនាស់ផលប្រយោជន៍ចូលរួមក្នុងការដោះស្រាយ*

*- ហាមដាច់ខាតនូវរាល់អំពើគំរាមកំហែង សងសឹកចំពោះអ្នកប្ដឹង និងសាក្សី*

*- មិនត្រូវបញ្ជូន ឬចម្លងខ្លឹមសារពាក្យបណ្ដឹងទាំងស្រុងទៅឲ្យមុខសញ្ញាដែលត្រូវគេប្ដឹងក្នុងករណីចាំបាច់គឺ គ្រាន់តែដក*

ស្រង់ខ្លឹមសារដែលពាក់ព័ន្ធ ទៅឲ្យអង្គការចាត់តាំងគណបក្សដែលមានសមត្ថកិច្ចពិនិត្យពិចារណា ។

**ខ- ករណីដែលត្រូវយកចិត្តទុកដាក់**

- ការដោះស្រាយបណ្តឹងបរិហារត្រូវជានា និងរក្សាឲ្យបានដាច់ខាតនូវលក្ខការណ៍ផ្ទៃក្នុងរបស់គណបក្ស

- ករណីដែលគណៈកម្មាធិការត្រួតពិនិត្យ រកឃើញកំហុសធ្ងន់របស់មុខសញ្ញាដែលគេប្តឹង ត្រូវបញ្ជូនទៅតុលាការ (ករណីទោសព្រហ្មទណ្ឌ) អង្គការចាត់តាំងគណបក្សដែលមានសមត្ថកិច្ចត្រូវប្រញាប់ប្រញាល់ដំណើរការដាក់វិន័យផ្នែកគណបក្ស ឲ្យបានរួចរាល់ជាមុនសិន (រូបភាពដកតួនាទី) និងបើមានទោសដល់កម្រិតជាប់ពន្ធនាគារអង្គការចាត់តាំងគណបក្សដែលមានសមត្ថកិច្ចត្រូវសម្រេចដាក់វិន័យមន្ត្រី សមាជិកគណបក្សនោះដោយរូបភាពបញ្ចេញពីសមាជិកគណបក្ស។

**៤.កំណត់មុខសញ្ញា**

**ក**.ត្រូវបំភ្លឺបញ្ជាក់ច្បាស់លាស់រឿងដែលត្រឹមត្រូវ ឬខុសធ្ងន់ដែលជាភារៈទទួលខុសត្រូវរបស់មុខសញ្ញាចំនួន ៣ប្រភេទ៖

- អ្នកត្រូវគេប្តឹងបរិហារ
- អ្នកប្តឹងបរិហារ
- អង្គការចាត់តាំងគណបក្សដែលគ្រប់គ្រងមន្ត្រី សមាជិកគណបក្សត្រូវគេប្តឹងបរិហារ។

ក្នុងករណីបណ្តឹងបរិហារត្រឹមត្រូវ ក្រោយពីបញ្ជាក់បានច្បាស់លាស់ រឿងដែលត្រឹមត្រូវរួចហើយ ត្រូវពិនិត្យអំពីភារកិច្ចអង្គការចាត់តាំងគណបក្សដែលគ្រប់គ្រងមុខសញ្ញាត្រូវគេប្តឹងបរិហារ (ការងារដឹកនាំ អប់រំសំខាន់គឺការងារគ្រប់គ្រង ការអនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍សេចក្តីសម្រេចចិត្តនានារបស់គណបក្ស)។

ប្រសិនបើបណ្តឹងបរិហារពុំត្រឹមត្រូវ ត្រូវយោងតាមសភាពការណ៍ជាក់ស្តែង ដើម្បីបកស្រាយ បើប្តឹងដោយការយល់ច្រឡំ ក៏ត្រូវមានការដោះស្រាយត្រឹមត្រូវ អប់រំ ណែនាំ ឬត្រូវដាក់វិន័យអ្នកប្តឹង។ ចំពោះសមាសភាពអាក្រក់ឆ្លៀតឱកាស ប្រើសិទ្ធិប្តឹងបរិហារដោយចេតនាមួលបង្កាច់ ប្រឌិត បំផ្លើសការពិត ចោទប្រកាន់លើមន្ត្រីសមាជិកគណបក្ស ឬអង្គការចាត់តាំងគណបក្សនោះ ត្រូវតែវិនិច្ឆ័យដាក់វិន័យម៉ឺងម៉ាត់ និងអាចប្តឹងទៅតុលាការ។

**២**.មន្ត្រី សមាជិកគណបក្សគ្រប់រូប អង្គការចាត់តាំងគណបក្សទាំងអស់ ដែលត្រូវគេប្តឹងបរិហារដោយរូបភាពណាក្តី សុទ្ធតែត្រូវបានត្រួតពិនិត្យដោះស្រាយ ប៉ុន្តែគណៈកម្មាធិការត្រួតពិនិត្យគណបក្សគ្រប់ថ្នាក់ចាំបាច់ត្រូវយោងតាមភារកិច្ច សិទ្ធិអំណាច និងទិសដៅភារកិច្ច គោលនយោបាយរបស់គណបក្ស ក្នុងដំណាក់កាលនីមួយៗ ដើម្បីកំណត់ច្បាស់លាស់មុខសញ្ញាណាចាំបាច់ ដែលត្រូវប្រមូលផ្តុំដោះស្រាយ។ មុនបង្អស់ចាំបាច់ត្រូវដោះស្រាយបណ្តឹង

បរិហារចំពោះមន្ត្រី សមាជិកគណបក្ស ដែលស្ថិតក្រោមការគ្រប់គ្រង របស់គណៈកម្មាធិការគណបក្សនៅថ្នាក់ខ្លួន ។

### ៥.វិធីដោះស្រាយបណ្តឹង

បណ្តឹងបរិហារមានខ្លឹមសារ និងមុខសញ្ញា ត្រូវគេប្តឹងបរិហារខុសៗគ្នា។ វិធីដោះស្រាយបណ្តឹងករណីនីមួយៗ ពុំអាចអនុវត្តដូចគ្នាបានទេ គឺត្រូវផ្អែកតាមសភាពការណ៍ និងសកម្មភាពជាក់ស្តែង ដើម្បីមានវិធានការដោះស្រាយត្រឹមត្រូវហ្មត់ចត់ និងទាន់ពេលវេលា ។

### ក.លក្ខការណ៍ដោះស្រាយបណ្តឹង

ការដោះស្រាយបណ្តឹងបរិហារចំពោះមន្ត្រី សមាជិកគណបក្ស អង្គការចាត់តាំងគណបក្សគឺ ជាការងារចាំបាច់របស់គណបក្ស និងជាជីវភាពផ្ទៃក្នុងគណបក្ស ត្រូវរក្សាឲ្យបានខ្ជាប់ខ្ជួននូវលក្ខការណ៍ដឹកនាំរបស់គណបក្ស។ ត្រូវក្តាប់ជាប់ និងអនុវត្តឲ្យបានល្អ វិធីសាស្ត្រជាមូលដ្ឋាននៃការងារត្រួតពិនិត្យគណបក្ស ត្រូវផ្អែកលើអង្គការចាត់តាំងគណបក្ស ពង្រីកស្មារតីភ្ញាក់រលឹករបស់សមាជិកគណបក្ស ចៀសវាងការប្រើប្រាស់រូបភាពគាបសង្កត់ ចាប់បង្ខំ បង្កឲ្យមានការសង្ស័យគ្នា ធ្វើឲ្យបែកបាក់សាមគ្គីផ្ទៃក្នុង ។

មន្ត្រីគណៈកម្មាធិការត្រួតពិនិត្យ ត្រូវលើកកម្ពស់ស្មារតីទទួលខុសត្រូវខ្ពស់ ហ្មត់ចត់ម៉ឺងម៉ាត់ នឹងនរ ដើម្បីដំណើរការត្រួតពិនិត្យឲ្យបានឆាប់រហ័ស មានការសន្និដ្ឋានច្បាស់លាស់ និងមានវិធានការដោះស្រាយទាន់ពេលវេលា។ ដាច់ខាតមិនត្រូវរក្សាទុក អូសបន្លាយ

ពេលវេលា ខ្ជាចការលំបាក គេចវេះ ក្រេងរអែង មិនហ៊ានដោះស្រាយនោះទេ ។

- មន្ត្រី សមាជិកគណបក្សដែលត្រូវគេប្តឹងបរិហារត្រូវបានត្រួតពិនិត្យនិងវាយការណ៍ចំពោះមុខអង្គការចាត់តាំងគណបក្ស (សាខាគណបក្ស គណៈកម្មាធិការសាខាគណបក្ស គណៈកម្មាធិការគណបក្ស) និងត្រូវបានអង្គការចាត់តាំងគណបក្សមានសមត្ថកិច្ច (សាខាគណបក្ស គណៈកម្មាធិការសាខាគណបក្ស គណៈកម្មាធិការគណបក្ស គណៈកម្មាធិការត្រួតពិនិត្យគណបក្ស) វាយតម្លៃ និងសន្និដ្ឋានច្បាស់លាស់ ។

- ប្រសិនបើខ្លឹមសារនៃបណ្តឹងបរិហារមិនត្រឹមត្រូវ ឬដោយមានការភ័ន្តច្រឡំ ប៉ុន្តែគ្មានគំនិតអាក្រក់ត្រូវបកស្រាយជាបន្ទាន់ឲ្យអ្នកប្តឹងបានជ្រាប ដើម្បីការពារកិត្តិយសឲ្យអង្គការចាត់តាំងគណបក្ស និងមន្ត្រី សមាជិកគណបក្សដែលត្រូវគេប្តឹងបរិហារ។ ផ្ទុយទៅវិញ បើខ្លឹមសារបណ្តឹងបរិហារមានគំនិតអាក្រក់ បង្ខូច ឬបំបាក់មុខមន្ត្រី សមាជិកគណបក្ស បង្កជាបក្ខពួក បំបែកបំបាក់សាមគ្គីភាពផ្ទៃក្នុង ប្រឌិតរឿងខុសឆ្គងដោយចេតនានោះ ត្រូវតស៊ូធ្វើឲ្យច្បាស់លាស់ ករណីចាំបាច់ខ្លះ ត្រូវតែត្រួតពិនិត្យដាក់វិន័យអ្នកប្តឹងឲ្យបានសមស្រប ឬអាចប្តឹងទៅតុលាការ ។

### ខ.ការបែងចែកប្រភេទបណ្តឹងបរិហារ

ត្រូវបែងចែកប្រភេទបណ្តឹងបរិហារដើម្បីកំណត់សមត្ថកិច្ចទទួលខុសត្រូវ និងចាំបាច់មានវិធានការដោះស្រាយចំពោះប្រភេទខ្លឹមសារបណ្តឹងនីមួយៗ មានផែនការត្រួតពិនិត្យ មុនឬក្រោយឬត្រូវបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចណាមួយ ដើម្បីដោះស្រាយ។ ចាំបាច់ត្រូវបែងចែកប្រភេទបណ្តឹងបរិហារដូចខាងក្រោម៖

- បណ្តឹងបរិហារ ដែលគណៈកម្មាធិការត្រួតពិនិត្យគណបក្សត្រូវពិនិត្យដោះស្រាយ
- បណ្តឹងបរិហារ ដែលចាំបាច់ត្រូវបញ្ជូនទៅស្ថាប័នផ្សេងៗដោះស្រាយ ។

### គ.អំពីការរៀបចំ

គណៈកម្មាធិការត្រួតពិនិត្យគណបក្ស ត្រូវរៀបចំការងារមួយចំនួនតាមលំដាប់លំដោយដូចខាងក្រោម៖

- សង្ខេបខ្លឹមសារបណ្តឹង
- ប្រភពផ្តល់ពាក្យបណ្តឹង
- ឈ្មោះមុខសញ្ញាដែលត្រូវគេប្តឹង តួនាទី អង្គភាព...
- បណ្តាបញ្ហាដែលអ្នកប្តឹងបានលើកឡើង បណ្តាភស្តុតាងនិងឯកសារពាក់ព័ន្ធ
- សំណូមពររបស់អ្នកប្តឹង

- សុំគោលការណ៍ពីគណៈកម្មាធិការគណបក្សដើម្បីចុះដោះស្រាយ

- រៀបចំគណៈប្រតិភូចុះត្រួតពិនិត្យ ដោះស្រាយបណ្ដឹងឲ្យបានសមស្រប ។

ដើម្បីដោះស្រាយបណ្ដឹងបរិហារឲ្យបានច្បាស់លាស់ ហ្មត់ចត់ និងទាន់ពេលវេលា គណៈកម្មាធិការត្រួតពិនិត្យគណបក្សត្រូវអនុវត្តឲ្យបានល្អនូវការងារមួយចំនួនដូចខាងក្រោម៖

- ក្រោយពេលដែលបានបែងចែកប្រភេទខ្លឹមសារ និងកំណត់ភារកិច្ចដោះស្រាយបណ្ដឹងបរិហាររួចហើយ ចាំបាច់ត្រូវធ្វើផែនការត្រួតពិនិត្យ ត្រូវប្រមូលផ្ដុំពិនិត្យជាមុននូវបណ្ដាខ្លឹមសារ និងមុខសញ្ញាសំខាន់ៗ

- កំណត់ច្បាស់នូវខ្លឹមសារបណ្ដាបញ្ហាចាំបាច់ និងកំណត់ពេលវេលាសម្រាប់ជួបធ្វើការជាមួយ ៖ អ្នកប្ដឹងបរិហារអ្នកត្រូវគេប្ដឹងបរិហារ និងអង្គការចាត់តាំងគណបក្ស ដែលមានមន្ត្រីសមាជិកគណបក្សត្រូវគេប្ដឹងបរិហារ

- ណែនាំ ផ្ដល់យោបល់ឲ្យអ្នកត្រូវគេប្ដឹងបរិហារធ្វើរបាយការណ៍ស្វ័យត្រួតពិនិត្យ(ចំពោះមុខអង្គការចាត់តាំងគណបក្ស)

- រៀបចំសំណុំលិខិត ឯកសារពាក់ព័ន្ធឲ្យបានគ្រប់គ្រាន់ និងច្បាស់លាស់ មានដូចជា៖ របាយការណ៍ត្រួតពិនិត្យផ្ទាល់ខ្លួន កំណត់ហេតុ និងបណ្ដាឯកសារដែលបានស្រាវជ្រាវ។

## ឃ.ផែនការសកម្មភាព

**ឃ.១**-ជួបជាមួយអ្នកប្តឹង ដើម្បីឲ្យគេបានបញ្ជាក់បន្ថែមនូវចំណុចអ្វីដែលពុំទាន់ច្បាស់លាស់ ចាំបាច់ត្រូវអប់រំអ្នកប្តឹងបរិហារ ឲ្យមានស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការរាយការណ៍ផ្តល់ព័ត៌មានឲ្យបានស្មោះត្រង់។ ស្រាវជ្រាវបញ្ហាណាដែលមានភស្តុតាងជាក់ស្តែង បញ្ហាណាដែលទើបនឹងកើតឡើងតាមពាក្យចចាមអារាម។

**ឃ.២**-ជួបជាមួយអង្គការចាត់តាំងគណបក្ស ដែលមុខសញ្ញាត្រូវគេប្តឹងកំពុងធ្វើសកម្មភាពផ្ទាល់ ឬអង្គការចាត់តាំងគណបក្សគ្រប់គ្រងមុខសញ្ញានោះ ដើម្បីឲ្យគេផ្តល់ព័ត៌មានផ្សេងៗដែលមានការពាក់ព័ន្ធ។

**ឃ.៣**-ជួបជាមួយមុខសញ្ញាដែលត្រូវគេប្តឹង ដើម្បីឲ្យគេបញ្ជាក់ទៅលើខ្លឹមសារបណ្តឹង និងចំណុចមួយចំនួនដែលយើងចង់ដឹង ដោយស្មារតីភ្ជាក់រឭកជាលាយលក្ខណ៍អក្សរ។ ពិនិត្យ និងបញ្ជាក់នូវចំណុចទាំងឡាយណា ដែលអ្នកត្រូវគេប្តឹងរាយការណ៍ពុំទាន់ច្បាស់លាស់ ឬពុំទាន់រាយការណ៍ ដែលមានខ្លឹមសារក្នុងបណ្តឹងបាននិយាយច្បាស់លាស់។ ម្យ៉ាងទៀតត្រូវផ្តើមយោបល់ ដើម្បីឲ្យអ្នកត្រូវគេប្តឹងបរិហារស្វ័យត្រួតពិនិត្យរាយការណ៍ដោយស្មោះត្រង់។

**ឃ.៤**-ជួបអ្នកដែលពាក់ព័ន្ធដឹងឮពីបញ្ហានោះ (មន្ត្រី សមាជិកគណបក្ស និងមហាជន) ទន្ទឹមនោះត្រូវអប់រំណែនាំ ដើម្បីឲ្យគេជួយផ្តល់យោបល់ និងឯកសារឲ្យបានត្រឹមត្រូវ។

ផ្តើមចេញពីចំណុចទាំងឡាយខាងលើ ត្រូវរកឲ្យឃើញនូវបញ្ហាអ្វីទៀត ដែលពុំទាន់ច្បាស់លាស់ ត្រូវស្រាវជ្រាវបញ្ជាក់បន្ថែម។

**ឃ.៥-** អង្គការចាត់តាំងគណបក្សមានសមត្ថកិច្ច (សាខាគណបក្ស គណៈកម្មាធិការគណបក្ស គណៈកម្មាធិការត្រួតពិនិត្យគណបក្ស) សន្និដ្ឋានលើខ្លឹមសារបណ្តឹង និងលទ្ធផលស្រាវជ្រាវ តើអ្នកត្រូវគេប្តឹងបរិហារមានការខុសឆ្គងយ៉ាងណាខ្លះ និងមានវិធានការដោះស្រាយ៖

- ប្រសិនបើបណ្តឹងបរិហារមានខ្លឹមសារមិនពិតប្រាកដដោយគ្រាន់តែឮពាក្យចចាមអារាម ឬ ដោយសារអ្នកប្តឹងភាន់ច្រឡំនោះ ចាំបាច់ត្រូវជួបជាមួយអ្នកត្រូវគេប្តឹងបរិហារសាឡើងវិញ ដើម្បីផ្តល់ព័ត៌មានពីលទ្ធផលនៃការងារត្រួតពិនិត្យ ឬជូនដំណឹងឲ្យគេបានជ្រាបព្រមទាំងក្រើនរំលឹកឲ្យគេខិតខំចៀសវាងធ្វើការងារណាដែលនាំឲ្យមានបញ្ហាភាន់ច្រឡំ ប៉ុន្តែបើមានការធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់កិត្តិយសរបស់អ្នកដែលត្រូវគេប្តឹងបរិហារនោះ អ្នកប្តឹងត្រូវធ្វើការសុំទោស។

- ប្រសិនបើខ្លឹមសារក្នុងបណ្តឹងបរិហារមានពិតមែន ប៉ុន្តែមិនជះឥទ្ធិពលដល់គណបក្ស ឬអង្គការចាត់តាំងគណបក្សទេនោះ ត្រូវស្នើគណៈកម្មាធិការគណបក្ស ដែលទទួលខុសត្រូវផ្ទាល់ចំពោះមុខសញ្ញាដែលត្រូវគេប្តឹង ជួយអប់រំ ណែនាំមន្ត្រី សមាជិកគណបក្សនោះចៀសវាងការប្រព្រឹត្តខុសឆ្គងធ្ងន់ធ្ងរ។

- ប្រសិនបើខ្លឹមសារក្នុងបណ្តឹងបរិហារ មានភាពត្រឹមត្រូវពិតប្រាកដមែន ដល់កម្រិតត្រូវតែដាក់វិន័យនោះ គឺត្រូវដំណើរការវិនិច្ឆ័យដាក់វិន័យ ឲ្យបានត្រឹមត្រូវតាមលក្ខការណ៍ទម្រង់បែបបទនៃការងារត្រួតពិនិត្យ ផ្អែកទៅលើលក្ខការណ៍ប្រមូលផ្តុំប្រជាធិបតេយ្យ ច្បាស់លាស់ និងយុត្តិធម៌ ដើម្បីសន្និដ្ឋានវាយតម្លៃកំហុសឆ្គង និងកំណត់រូបភាពវិន័យឲ្យបានសមស្រប។

## ខ.ការងារបញ្ចប់ការដោះស្រាយបណ្តឹង

ពេលដោះស្រាយចប់សព្វគ្រប់នូវបណ្តឹងបរិហារ គណៈប្រតិភូចុះត្រួតពិនិត្យត្រូវបំពេញការងារមួយចំនួន ដូចខាងក្រោមដើម្បីបញ្ចប់សំណុំរឿងដោះស្រាយបណ្តឹងបរិហារៈ

- រៀបចំសំណុំឯកសារ និងធ្វើរបាយការណ៍ជូនគណៈកម្មាធិការត្រួតពិនិត្យ និង គណៈកម្មាធិការគណបក្ស ដែលបានប្រគល់ភារកិច្ចឲ្យត្រួតពិនិត្យដើម្បីពិនិត្យសម្រេច។

- គណៈកម្មាធិការត្រួតពិនិត្យគណបក្ស ត្រូវជូនដំណឹងឲ្យអ្នកប្តឹងបានជ្រាបអំពីលទ្ធផលដែលបានដោះស្រាយ។

- ត្រូវប្រជុំបូកសរុបដកពិសោធន៍អំពីកិច្ចដំណើរការការងារ ដើម្បីដកស្រង់បាននូវគុណសម្បត្តិការខ្វះខាត ដែលត្រូវកែលម្អព្រមទាំងដកពិសោធន៍អំពីការងារអប់រំ ណែនាំ និងការងារគ្រប់គ្រងសមាជិកគណបក្ស ។

## III-បណ្ដឹងតវ៉ា

*ការប្ដឹងតវ៉ាអំពីការដាក់វិន័យ របស់អង្គការចាត់តាំងគណបក្ស និងមន្ត្រី សមាជិកគណបក្សគឺជាការអនុវត្តនូវសិទ្ធិរបស់អង្គការចាត់តាំងគណបក្ស និងមន្ត្រី សមាជិកគណបក្សដែលបានកំណត់ក្នុងលក្ខន្តិកៈរបស់គណបក្សជំពូកIIIមាត្រាទី៨ ចំណុច៣ សមាជិកគណបក្សមានសិទ្ធិ "**លើកមតិតវ៉ារបស់ខ្លួន ទៅគណៈកម្មាធិការនៃគណបក្សគ្រប់ថ្នាក់**"។ បទបញ្ជាផ្ទៃក្នុងរបស់គណបក្សជំពូកXប្រការ៣០ "**សមាជិក ឬអង្គការចាត់តាំងគណបក្ស ដែលត្រូវទទួលការត្រួតពិនិត្យដាក់វិន័យ មានសិទ្ធិធ្វើការបញ្ជាក់បំភ្លឺ ការពារខ្លួននៅចំពោះមុខសមត្ថកិច្ចដាក់វិន័យ។ ក្នុងករណីមិនសុខចិត្ត ចំពោះរូបភាពវិន័យដែលត្រូវទទួល សមាជិក ឬអង្គការចាត់តាំងគណបក្សនោះ មានសិទ្ធិតវ៉ាឡើងគណបក្សថ្នាក់លើ**" ។*

### ១.អត្ថន័យនៃបណ្ដឹងតវ៉ា

*បណ្ដឹងតវ៉ាមានអត្ថន័យដូចតទៅៈ*

*- ការដោះស្រាយបណ្ដឹងតវ៉ា អំពីការដាក់វិន័យរបស់គណបក្សគឺស្ដែងឡើងនូវការគោរព និងការពារសិទ្ធិប្រជាធិបតេយ្យរបស់សមាជិកគណបក្ស ដើម្បីពង្រឹងចំណងទាក់ទងរវាងមន្ត្រី សមាជិក គណបក្ស និងអង្គការចាត់តាំងគណបក្ស។*

*- ការប្ដឹងតវ៉ាជាសិទ្ធិត្រឹមត្រូវរបស់សមាជិកគណបក្ស ដែលបានកំណត់ក្នុងលក្ខន្តិកៈគណបក្សជំពូកIIIមាត្រាទី៨ ដែលបង្ហាញ*

ឡើងនូវទំនុកចិត្តរបស់មន្ត្រី សមាជិកគណបក្សចំពោះគណបក្ស។ គណបក្សគោរព និងធានានូវសិទ្ធិប្រជាធិបតេយ្យរបស់សមាជិក ថែរក្សាការពាររបៀបរៀបរយ ភាពម៉ឺងម៉ាត់នៃវិន័យរបស់គណបក្ស។

- ការដោះស្រាយបណ្តឹងតវ៉ា ជាឱកាសដើម្បីឲ្យអង្គការចាត់តាំងគណបក្ស ស្ទ័យត្រួតពិនិត្យ និងត្រួតពិនិត្យថ្នាក់ក្រោមក្នុងការអនុវត្តវិន័យរបស់គណបក្សតាមលក្ខការណ៍ និងទម្រង់បែបបទនៃការដាក់វិន័យ ដើម្បីកែលម្អ ដកស្រង់បទពិសោធន៍ការងារ និងធ្វើឲ្យការអនុវត្តការងាររបស់គណបក្សកាន់តែមានប្រសិទ្ធភាព លើកកម្ពស់ការយល់ដឹងអំពីស្មារតីទទួលខុសត្រូវ របៀបរបបធ្វើការងារ ធានាឲ្យការដាក់វិន័យរបស់គណបក្សត្រឹមត្រូវល្អ ប្រឆាំងរាល់បាតុភាពអសកម្ម ភាពលម្អៀង ហើយកែប្រែទាន់ពេល វេលារាល់ចំណុចខ្វះខាតទាំងនោះ។

- គណបក្សបានកំណត់នូវភារកិច្ចទទួលខុសត្រូវរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ក្នុងការទទួល និងដោះស្រាយបណ្តឹងតវ៉ាពីមន្ត្រី សមាជិកគណបក្ស អំពីការដាក់វិន័យយោងសេចក្តីសម្រេចលេខ ១០២៥/១៥ សស.គក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥និងលេខ១២៥៤/១៥ សស.គក ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ របស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស្តីពីការកែសម្រួលភារកិច្ច សិទ្ធិអំណាច រចនាសម្ព័ន្ធចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការត្រួតពិនិត្យនៃគណៈកម្មាធិការកណ្តាល និងគណៈ

កម្មាធិការត្រួតពិនិត្យគណបក្សក្រសួងស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**បណ្ដឹងតវ៉ាអាចកើតមានឡើងអាស្រ័យ ដោយមូលហេតុដូចតទៅ ៖**

**ក-អង្គការចាត់តាំងគណបក្ស**

- ការអប់រំមន្ត្រី សមាជិកគណបក្សដែលមានការខុសឆ្គងពុំទាន់បានល្អ

- ការអនុវត្តលក្ខការណ៍ និងទម្រង់បែបបទក្នុងការដាក់វិន័យមានការខ្វះខាត។

**ខ-មន្ត្រី សមាជិកគណបក្ស ដែលត្រូវវិន័យ**

- ដោយពុំបានដឹងខ្លួន ថាមានកំហុស
- ដោយយល់ថា ការដាក់វិន័យធ្ងន់ពេក
- ដោយសុំការអនុគ្រោះពីគណបក្ស
- មានការខ្វះខាតតែគេអាចកែប្រែបាន ។

ពេលទទួលបានបណ្ដឹងតវ៉ា អំពីការដាក់វិន័យរបស់គណបក្សដាច់ខាតមិនត្រូវតម្កល់ទុកចោល បញ្ជូនចុះឡើង ឬសម្ងំតគំរាមកំហែងអ្នកតវ៉ា ត្រូវចាត់តាំងត្រួតពិនិត្យដោះស្រាយឲ្យបានទាន់ពេលវេលា ។

## ២- នីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ា

គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ត្រូវជួយគណៈកម្មាធិការគណបក្សថ្នាក់ខ្លួន និងណែនាំអង្គការចាត់តាំងគណបក្សថ្នាក់ក្រោម ពិនិត្យវិនិច្ឆ័យដាក់វិន័យឲ្យបានត្រឹមត្រូវយុត្តិធម៌ ច្បាស់លាស់ និងទាន់ពេលវេលា គោរពតាមលក្ខការណ៍ទម្រង់បែបបទនៃការដាក់វិន័យរបស់គណបក្ស។ បង្កើនការងារត្រួតពិនិត្យអង្គការចាត់តាំងគណបក្សថ្នាក់ក្រោមក្នុងការដាក់វិន័យចំពោះមន្ត្រី សមាជិកគណបក្ស ដើម្បីកាត់បន្ថយដល់កម្រិតទាបបំផុតនូវបណ្តឹងតវ៉ាអំពីការដាក់វិន័យរបស់សមាជិកគណបក្ស ។

### ក-ការបែងចែកបណ្តឹងតវ៉ា

បណ្តឹងតវ៉ាមានច្រើនប្រភេទ ៖បណ្តឹងតវ៉ាអំពីការដាក់វិន័យគណបក្ស បណ្តឹងតវ៉ាអំពីវិន័យខាងផ្នែករដ្ឋបាល បណ្តឹងតវ៉ាអំពីការដាក់វិន័យផង និងបណ្តឹងបរិហារចំពោះសមាជិកគណបក្ស និងអង្គការចាត់តាំងគណបក្សផង បណ្តឹងតវ៉ាអំពីការទាមទារសិទ្ធិផ្សេងៗ តវ៉ាអំពីផលប្រយោជន៍។ល។ ត្រូវបែងចែកបណ្តឹងដែលជាសមត្ថកិច្ចដោះស្រាយរបស់គណៈកម្មាធិការត្រួតពិនិត្យ និងបណ្តឹងដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យ។ គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ពិនិត្យដោះស្រាយចំពោះតែបណ្តឹងតវ៉ាអំពីការអនុវត្តវិន័យក្នុងគណបក្សប៉ុណ្ណោះ ចំពោះបណ្តឹងតវ៉ាដែលមានខ្លឹមសារផ្សេងៗទៀត ត្រូវបញ្ជូនទៅឲ្យស្ថាប័នដែលមានភារកិច្ចទទួលខុសត្រូវ

ឬមានសមត្ថកិច្ចដោះស្រាយ និងជូនដំណឹងដល់អ្នកប្តឹងតវ៉ាឲ្យបានជ្រាប ។

**ក.១-បណ្តឹងតវ៉ាត្រូវដោះស្រាយជាអាទិភាព៖**

- ករណីរូបភាពដាក់វិន័យដោយបញ្ចេញពីសមាជិកគណបក្ស
- ករណីអ្នកប្តឹងតវ៉ាកំពុងបំពេញភារកិច្ចសំខាន់ៗ របស់ប្រទេសជាតិ

**ក.២-បណ្តឹងតវ៉ាមិនត្រូវដោះស្រាយ ៖**

- សេចក្តីសម្រេចដាក់វិន័យរបស់គណៈកម្មាធិការកណ្តាល
- អង្គការចាត់តាំងគណបក្សថ្នាក់ក្រោម និងគណៈកម្មាធិការត្រួតពិនិត្យថ្នាក់ក្រោម គ្មានសិទ្ធិដោះស្រាយចំពោះពាក្យប្តឹងតវ៉ាអំពីការដាក់វិន័យដែលអង្គការចាត់តាំងគណបក្សថ្នាក់លើ បានសម្រេចរួចហើយ។

**ខ-ផែនការសកម្មភាព**

ដំណើរការដោះស្រាយបណ្តឹងតវ៉ាអំពីការដាក់វិន័យ ជាការងារចាំបាច់ និងស្មុគស្មាញ ព្រោះជាការងារដែលបានអូសបន្លាយរយៈពេលយូរថ្ងៃ បានឆ្លងតាមការពិនិត្យវិនិច្ឆ័យដាក់វិន័យជាច្រើនថ្នាក់ និងមានករណីខ្លះក្រោយពេលសម្រេចដាក់វិន័យហើយមានបញ្ហាបណ្តាលឲ្យបែកបាក់សាមគ្គីភាពផ្ទៃក្នុង កាន់តែស្មុគស្មាញជាងមុនថែមទៀត ។

ចំពោះអ្នកប្ដឹងតវ៉ាភាគច្រើន ក្នុងបណ្ដឹងតែងតែរៀបរាប់ពីគុណសម្បត្តិ និងស្នាដៃដែលបានអនុវត្តកន្លងមក រីឯចំណុចខ្វះខាតខុសឆ្គងរបស់ខ្លួន មិនសូវបានលើកឡើងច្បាស់លាស់ និងមានការពាក់ព័ន្ធដល់បណ្ដាអង្គការចាត់តាំងគណបក្ស និងមន្ត្រី សមាជិកគណបក្សដែលចូលរួមក្នុងការពិនិត្យវិនិច្ឆ័យផងដែរ ។

ការដោះស្រាយបណ្ដឹងតវ៉ា ចាំបាច់មានការទំនាក់ទំនងផ្ទាល់ជាមួយអ្នកប្ដឹងតវ៉ាបណ្ដាអង្គការចាត់តាំងគណបក្ស និងសមាជិកគណបក្សផ្សេងៗទៀត ដែលបានចូលរួមវិនិច្ឆ័យដាក់វិន័យ ។

ដើម្បីដោះស្រាយឲ្យបានត្រឹមត្រូវ និងហ្មត់ចត់ នូវបណ្ដឹងតវ៉ាអំពីការដាក់វិន័យរបស់សមាជិកគណបក្ស ចាំបាច់ត្រូវអនុវត្តការងារមួយចំនួនដូចខាងក្រោម ៖

**ខ.១-រៀបចំផែនការ**

- ពិនិត្យ ស្រាវជ្រាវខ្លឹមសារបណ្ដឹងតវ៉ាឲ្យបានហ្មត់ចត់ ប្រមូលឯកសារដែលមានការពាក់ព័ន្ធ ដើម្បីស្វែងយល់ខ្លឹមសារនៃបណ្ដឹងមូលហេតុនិងសំណូមពររបស់អ្នកប្ដឹងតវ៉ា
- សុំគោលការណ៍ពីគណៈកម្មាធិការគណបក្ស
- រៀបចំគណៈប្រតិភូនិងជ្រើសរើសសមាសភាព ដើម្បីចុះត្រួតពិនិត្យដោះស្រាយឲ្យបានសមស្រប។

## ១.២-នីតិវិធីដោះស្រាយបណ្តឹងតវ៉ា

### *១.២.១-ជួបជាមួយអង្គការចាត់តាំងគណបក្ស ដែលបានសម្រេចដាក់វិន័យ និងដោះស្រាយពីលើកមុនៈ*

*- ជម្រាបឲ្យបានច្បាស់លាស់ពីខ្លឹមសារតវ៉ាយោបល់ និងសំណូមពររបស់អ្នកប្តឹង*

*- ស្វែងយល់ការងារដែលអង្គការចាត់តាំងគណបក្ស បានធ្វើកន្លងមកដើម្បីឈានដល់ការសម្រេចដាក់វិន័យ ឬ ដោះស្រាយបណ្តឹងតវ៉ា(បើមាន)*

*- ត្រូវយកចិត្តទុកដាក់ស្វែងយល់គុណសម្បត្តិ និងការខុសឆ្គងរបស់អ្នកប្តឹងតវ៉ា ដើម្បីវាយតម្លៃ និងសន្និដ្ឋាន*

*- ប្រមូលផ្តុំសំណុំឯកសារដាក់វិន័យ ឬសំណុំឯកសារដោះស្រាយបណ្តឹងតវ៉ាលើកមុន (បើមាន) ដើម្បីពិនិត្យស្រាវជ្រាវ។ ការស្រាវជ្រាវសំណុំឯកសារដាក់វិន័យ ត្រូវធ្វើឲ្យបានល្អិតល្អន់ និងហ្មត់ចត់បំផុត ចាំបាច់ត្រូវប្រៀបធៀបជាមួយខ្លឹមសារបណ្តឹង ដើម្បីពិនិត្យបញ្ហាណាដែលខុសគ្នា ចំណុចដែលមិនទាន់ច្បាស់លាស់ត្រូវពិនិត្យបញ្ជាក់បន្ថែម ។*

### *១.២.២-ជួបអ្នកប្តឹងតវ៉ាលើកដំបូង*

*- ស្វែងយល់ចិត្តគំនិត សតិអារម្មណ៍ អាកប្បកិរិយា និងសំណូមពររបស់គេ*

- អ្នកប្ដឹងតវ៉ារៀបរាប់បញ្ជាក់ឲ្យបានច្បាស់លាស់ នូវខ្លឹមសារតវ៉ា (បញ្ជាក់ឲ្យបានច្បាស់ពីការខុសគ្នារវាងសេចក្ដីសម្រេចដាក់វិន័យ និងខ្លឹមសារតវ៉ា)

- សំណូមពរឲ្យអ្នកប្ដឹងតវ៉ាសរសេរជាលាយលក្ខណ៍អក្សរ ដើម្បីបំពេញបន្ថែមចូលសំណុំលិខិត។

ការជួបអ្នកប្ដឹងតវ៉ាលើកដំបូងនេះ សំដៅជួយគេឲ្យឃើញច្បាស់នូវការខុសឆ្គង គុណវិបត្តិរបស់ខ្លួន ដើម្បីមានអាកប្បកិរិយាត្រឹមត្រូវក្នុងការអនុវត្តសេចក្ដីសម្រេចចិត្តដាក់វិន័យជាមួយនោះលើកទឹកចិត្តឲ្យគេខិតខំបន្តបំពេញភារកិច្ច នឹងនរចិត្ត ជឿទុកចិត្តលើការពិនិត្យវិនិច្ឆ័យ និងការដោះស្រាយរបស់គណបក្ស (ត្រូវជួបសាមីខ្លួននៅកន្លែងធ្វើការ)។

**១.២.៣-ជួបអង្គការចាត់តាំងគណបក្ស និងអ្នកដឹងឮកិច្ចការនេះ**

-ជួបជាមួយអង្គការចាត់តាំងគណបក្ស ឬអ្នកដែលបានដឹងឮកិច្ចការនេះ ដើម្បីពិនិត្យបញ្ជាក់កិច្ចការសំខាន់ៗ សំណូមពរឲ្យគេបំភ្លឺ រាល់បណ្ដាចំណុចខុសគ្នារវាងខ្លឹមសារសេចក្ដីសម្រេច និងបណ្ដឹងតវ៉ា (បញ្ហាចាំបាច់ត្រូវពិនិត្យបញ្ជាក់ឲ្យបានច្បាស់)។

-ត្រូវរក្សាទុកក្នុងសំណុំលិខិត ដោយត្រូវធ្វើជាលាយលក្ខណ៍អក្សរ កត់ត្រាឲ្យបានច្បាស់យោបល់អ្នករាយការណ៍ផ្ដល់ព័ត៌មាន និងមានចុះហត្ថលេខា ឬស្នាមមេដៃបញ្ជាក់ទទួលស្គាល់។ ករណី

ចាំបាច់ត្រូវប្រមូលផ្ដុំបន្ថែមនូវឯកសារជាកស្ដុតាងសំណូមពរឲ្យផ្ដល់ឯកសារច្បាប់ដើមឬច្បាប់ចម្លង ហើយត្រូវតែចុះហត្ថលេខាឬស្នាមមេដៃទទួលស្គាល់ ។

**១.២.៤-ជួបអង្គការចាត់តាំងគណបក្ស និងស្ថាប័នដែលគ្រប់គ្រងអ្នកប្ដឹងតវ៉ា**

ស្វែងយល់ពីសកម្មភាពបំពេញការងាររបស់អ្នកប្ដឹង ការគោរពលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងគណបក្ស ការអនុវត្តគោលនយោបាយកម្មវិធីនយោបាយគោលការណ៍ សេចក្ដីសម្រេចរបស់គណបក្ស ចាប់ពីពេលត្រូវបានដាក់វិន័យ ។

**១.២.៥-ជួបអ្នកប្ដឹងតវ៉ាលើកចុងក្រោយ**

ក្រោយពេលដែលបានស្រាវជ្រាវ និងត្រួតពិនិត្យច្បាស់លាស់ហើយត្រូវជួបជាមួយអ្នកប្ដឹងតវ៉ាឡើងវិញដើម្បីវិភាគ និងកំណត់យោបល់របស់គេ។

ត្រូវឈរលើមូលដ្ឋានអប់រំបញ្ចុះបញ្ចូល និងផ្ដើមចេញពីមនោសញ្ចេតនាស្រឡាញ់រាប់អាន ចៀសវាងមានគំនុំគុំគួន ឬមានអាកប្បកិរិយាតឹងតែង ចាប់បង្ខំ អ្នកប្ដឹងតវ៉ាឲ្យទទួលស្គាល់ និងឃើញច្បាស់កំហុសឆ្គងរបស់ខ្លួន ។

ចាំបាច់ត្រូវពន្យល់ណែនាំឲ្យគេយល់ច្បាស់ នូវលទ្ធផលការងារដែលបានស្រាវជ្រាវ បើគ្មានអ្វីខុសពីខ្លឹមសារសេចក្ដីសម្រេចដាក់វិន័យមុននោះទេ (វិនិច្ឆ័យដាក់វិន័យត្រឹមត្រូវ តែសាមីខ្លួនយល់

ប្រទ្បំ ថ្នាំងថ្នាក់ មិនត្រឹមត្រូវ) គឺត្រូវណែនាំឲ្យគេយល់ព្រមទទួលការដាក់វិន័យ និងណែនាំគេឲ្យធ្វើលិខិតព្រមទទួលវិន័យ រួចត្រូវរាយការណ៍ជូនគណៈកម្មាធិការគណបក្ស ដែលគ្រប់គ្រងសមាជិកគណបក្សនោះឲ្យបានជ្រាប។

## ខ.២.៦-ការងារបញ្ចប់ការដោះស្រាយបណ្តឹងតវ៉ា

ករណីដែលគណៈកម្មាធិការត្រួតពិនិត្យរកឃើញ លទ្ធផលមិនសមស្របនឹងសេចក្តីសម្រេចដាក់វិន័យ ត្រូវស្នើអង្គការចាត់តាំងគណបក្សដែលបានសម្រេចដាក់វិន័យ ប្រជុំវិនិច្ឆ័យវិន័យឡើងវិញ ដើម្បីវិភាគ និងសន្និដ្ឋានឲ្យបានច្បាស់លាស់ត្រឹមត្រូវ និងប្រកបដោយតម្លាភាព លើបញ្ហានីមួយៗ និងសន្និដ្ឋានកែប្រែ ឬមិនកែប្រែរូបភាពវិន័យដែលបានអនុវត្តរួចហើយ។

គណៈប្រតិភូត្រួតពិនិត្យ ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលការស្រាវជ្រាវត្រួតពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយ និងប្រជុំក្រុមការងារ ដើម្បីវាយតម្លៃ និងដកស្រង់បទពិសោធន៍ក្នុងការដោះស្រាយបណ្តឹងតវ៉ា។ របាយការណ៍ដោះស្រាយបណ្តឹងតវ៉ា បានធ្វើគ្រប់ជ្រុងជ្រោយហើយត្រូវរាយការណ៍ជូនគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការគណបក្សថ្នាក់ខ្លួន ដើម្បីពិនិត្យ និងសម្រេច។

## គ-ពិនិត្យសម្រេច និងប្រកាសសេចក្ដីសម្រេច

*ក្រោយពេល ដែលគណៈកម្មាធិការគណបក្សបានចេញសេចក្ដីសម្រេចរួចហើយគណៈកម្មាធិការត្រួតពិនិត្យ ត្រូវបំពេញការងារមួយចំនួនដូចខាងក្រោម ៖*

*-ផ្ញើសេចក្ដីសម្រេចជូនអ្នកប្ដឹងតវ៉ា និងបណ្ដាអង្គការចាត់តាំងគណបក្ស ដែលមានការពាក់ព័ន្ធដើម្បីអនុវត្ត។ ករណីចាំបាច់គប្បីអញ្ជើញអ្នកប្ដឹងតវ៉ាមកប្រកាសពីលទ្ធផលដោះស្រាយ និងជូនសេចក្ដីសម្រេច ។*

*- សាខាគណបក្ស ឬ អង្គការចាត់តាំងគណបក្ស ដែលគ្រប់គ្រងសមាជិកនោះ ត្រូវធ្វើពិធីប្រកាសសេចក្ដីសម្រេចថ្មី ។*

*វិធីដោះស្រាយបណ្ដឹងតវ៉ាដែលល្អគឺ ក្នុងករណីដែលលទ្ធផលស្រាវជ្រាវត្រូវកែប្រែ ឬលុបចោលរូបភាពវិន័យដែលអង្គការចាត់តាំងគណបក្សថ្នាក់ក្រោមបានអនុវត្តហើយនោះ គណៈកម្មាធិការត្រួតពិនិត្យត្រូវណែនាំឲ្យអង្គការចាត់តាំងគណបក្ស ដែលចេញសេចក្ដីសម្រេចនោះម្ចាស់ការចេញសេចក្ដីសម្រេចជាថ្មី កែប្រែរូបភាពវិន័យឲ្យបានត្រឹមត្រូវឡើងវិញ ។*

*សំណុំលិខិតដោះស្រាយបណ្ដឹងតវ៉ា (រួមមានទាំងបណ្ដាលិខិតស្នាម ជាលាយលក្ខណ៍អក្សរវិនិច្ឆ័យដោះស្រាយគ្រាដំបូង) ត្រូវបានរក្សាទុកឲ្យបានហ្មត់ចត់ ។*

*«សេចក្តីសម្រេចដាក់វិន័យ ត្រូវកត់ត្រាទុកក្នុងសំណុំឯកសារផ្ទាល់របស់សមាជិកគណបក្ស និងសមាជិកគ្រប់រូបនៃអង្គការចាត់តាំងគណបក្សដែលត្រូវទទួលវិន័យ»* បទបញ្ជាផ្ទៃក្នុងគណបក្សជំពូកXប្រការ៣០( ។

**កំណត់សម្គាល់៖** *ចំពោះករណីបណ្តឹងតវ៉ាផង ប្តឹងបរិហារផង គណៈកម្មាធិការត្រួតពិនិត្យត្រូវថ្លឹងថ្លែង ឲ្យបានហ្មត់ចត់ ដើម្បីអាចដោះស្រាយព្រមគ្នាតែម្តងក៏បាន ។*

**IV-សេចក្តីសន្និដ្ឋាន**

*ការដោះស្រាយបណ្តឹងបរិហារ និងបណ្តឹងតវ៉ារបស់សមាជិកគណបក្ស គឺជាភារៈទទួលខុសត្រូវរបស់អង្គការចាត់តាំងគណបក្សមន្ត្រីសមាជិកគណបក្ស និងជាភារកិច្ចសំខាន់របស់គណៈកម្មាធិការត្រួតពិនិត្យគណបក្សគ្រប់ថ្នាក់ ដែលបានចែងនៅក្នុងសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាលលេខ ១០២៥/១៥ សស.គក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ និងលេខ ១២៥៤/១៥ សស.គក ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ ២០១៥។*

*ការដោះស្រាយបណ្តឹង ត្រូវភ្ជាប់ជាប់នូវគោលការណ៍ កម្មវិធីនយោបាយ និងសេចក្តីសម្រេចចិត្តនានា ទិសដៅភារកិច្ចរបស់គណបក្សដំណាក់កាលនីមួយៗ ច្បាប់របស់រដ្ឋ និងតួនាទី ភារកិច្ចទទួលខុសត្រូវរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ដោយឈរលើមូលដ្ឋានយុត្តិធម៌ច្បាស់លាស់ពិតប្រាកដ និងទាន់ពេលវេលា ។*

អនុវត្តការកិច្ចនេះបានល្អ ជាការរួមចំណែកកសាងគណបក្ស ពង្រឹងអង្គការចាត់តាំងគណបក្ស និងមន្ត្រី សមាជិកគណបក្ស ក្នុងការគោរព អនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និងសេចក្តីសម្រេចចិត្តនានារបស់គណបក្ស សំដៅរក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុង និងពង្រឹងវិន័យរបស់គណបក្ស ៕